ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ឯកសារ
# បំណិនផ្តល់ព័ត៌មានត្រឡប់



នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ
ឆ្នាំ ២០១៦

# ឯកសារ
# បំណិនផ្តល់ព័ត៌មានត្រឡប់

នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ
ឆ្នាំ ២០១៦

# ឯកសារបំណិនផ្តល់ព័ត៌មានត្រឡប់

ផ្នែកទី១៖ លក្ខណសម្បត្តិ និងភារកិច្ចរបស់គ្រូឧទ្ទេស និងគ្រូប្រចាំថ្នាក់
ផ្នែកទី២៖ ការផ្តល់ព័ត៌មានត្រឡប់
ផ្នែកទី៣៖ ជំហាននៃការផ្តល់ព័ត៌មានត្រឡប់
ផ្នែកទី៤៖ ការរៀបចំដំណើរការផ្តល់ព័ត៌មានត្រឡប់

បោះពុម្ពផ្សាយដោយ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា

បោះពុម្ពនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៦

ឯកសារនេះត្រូវបានចងក្រងនិងបោះពុម្ពផ្សាយក្រោមការឧបត្ថម្ភថវិការបស់អគ្គលេខាធិការដ្ឋានសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍ និងជំនួយមនុស្សធម៌ (DGD) និងជំនួយផ្នែកបច្ចេកទេសរបស់ការិយាល័យហ្វ្លេមីស៍សម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍ និងជំនួយការបច្ចេកទេស (VVOB) ។ ខ្លឹមសារនៃការបោះពុម្ពផ្សាយនេះ មិនស្ថិតនៅក្រោមការទទួលខុសត្រូវរបស់រដ្ឋាភិបាលហ្វ្លេមីស៍ និងរដ្ឋាភិបាលប៊ែលហ្ស៊ិកឡើយ ។

## កំណត់សម្គាល់កម្មសិទ្ធិបញ្ញា

រាល់ការបោះពុម្ពផ្សាយឯកសារត្រូវបានធ្វើឡើងដោយអនុលោមតាមអាជ្ញាប័ណ្ណៈ

Creative Commons Attribution-Non Commercial-Share Alike 3.0 Unported License

លើកលែងតែឯកសារដែលមិនបានរាប់បញ្ចូល និងបញ្ជីរក្សាសិទ្ធិខាងក្រោម ។ មានន័យថាអ្នកអាចចែកចាយ ថតចម្លង ប្រែសម្រួល និងយកលំនាំតាមឯកសារនេះក្នុងន័យមិនរកកម្រៃដោយពុំចាំបាច់ស្នើសុំការអនុញ្ញាតជាមុនពីអ្នកបោះពុម្ពផ្សាយឡើយ តែប្រសិនបើអ្នកបង្កើតឬកែប្រែថ្មីអ្នកត្រូវតែសុំអាជ្ញាបណ្ណ័ពីម្ចាស់ដើមក្នុងលក្ខខណ្ឌដូចគ្នាដែលបានបញ្ជាក់ខាងលើ ។ សម្រាប់ព័ត៌មានបន្ថែមអំពីអាជ្ញាប័ណ្ណខាងលើ សូមចូលទៅកាន់គេហទំព័រ

http://creativecommons.org/licenses/by-nc-sa/3.0

## ឯកសារមិនរាប់បញ្ចូល និងរក្សាសិទ្ធិ

ឯកសារមួយចំនួនក្នុងការបោះពុម្ពផ្សាយនេះមិនស្ថិតនៅក្រោមអាជ្ញាប័ណ្ណខាងលើឡើយ ។ ទាំងនេះគឺជាឯកសាររបស់ភាគីទី៣ដែលត្រូវប្រើប្រាស់ដោយត្រឹមត្រូវនិងទទួលបានការអនុញ្ញាត ។ អ្នកបោះពុម្ពផ្សាយមិនទទួលខុសត្រូវចំពោះលក្ខខណ្ឌច្បាប់ណាមួយ (រួមបញ្ចូលទាំងការធ្វេសប្រហែស) ចំពោះការបាត់បង់ ឬខូចខាតដែលកើតមានឡើងដោយការប្រើប្រាស់ផ្នែកណាមួយនៃឯកសារដែលទទួលបានពីភាគីទី៣ឡើយ។

# បុព្វកថា

បច្ចុប្បន្ននេះ ក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងក្លាទៅលើការអភិវឌ្ឍធនធានមនុស្សឱ្យស្របតាមការវិវត្តនៃសង្គមជាតិ។ ការអភិវឌ្ឍសមត្ថភាពរបស់គ្រូបង្រៀនគឺជាកត្តាចាំបាច់ដើម្បីសម្រេចគោលដៅអប់រំជាតិ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ ទន្ទឹមនឹងនេះការបណ្តុះបណ្តាលគ្រូបង្រៀនត្រូវបានយកចិត្តទុកដាក់ពង្រឹងគុណភាពការបង្រៀន និងរៀន ប្រកបដោយប្រសិទ្ធភាពនៅតាមសាលាគរុកោសល្យ និងវិក្រឹតការរាជធានី ខេត្ត។

ដើម្បីឆ្លើយតបទៅនឹងបរិបទខាងលើ ក្រសួងអប់រំ យុវជន និងកីឡា បានចងក្រងឯកសារស្តីពីបំណិនផ្តល់ព័ត៌មានត្រឡប់សម្រាប់គណៈកម្មការដឹកនាំកម្មសិក្សាគរុកោសល្យ គណៈគ្រប់គ្រងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន គ្រូឧទ្ទេស គ្រូប្រចាំថ្នាក់ និងគរុសិស្សប្រើប្រាស់ជាមធ្យោបាយក្នុងការលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពនៃសកម្មភាពបង្រៀន និងរៀនរបស់ខ្លួន ។

លើសពីនេះ ឯកសារស្តីពីបំណិនផ្តល់ព័ត៌មានត្រឡប់ ក៏បានជួយរួមចំណែកក្នុងការលើកកម្ពស់សមត្ថភាពយល់ដឹង និងការអនុវត្តរបស់កម្មសិក្សាការី ការិនី លើការងារបង្រៀន និងរៀនស្របតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមថាលោកគ្រូ អ្នកគ្រូទាំងអស់ នឹងយកចិត្តទុកដាក់អនុវត្ត និងប្រើប្រាស់ឯកសារនេះឱ្យអស់លទ្ធភាព ក្នុងការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងប្រសិទ្ធភាព ។

ជាទីបញ្ចប់ ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមការងារចងក្រងឯកសារ និងអង្គការVVOB ដែលបានយកចិត្តទុកដាក់អស់ពីកម្លាំងកាយ ចិត្ត បញ្ញា ស្មារតី ក្នុងការរៀបចំចងក្រងឯកសារដ៏មានសារៈសំខាន់នេះ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ២០១៦

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិត ហង់ ជួន ណារ៉ុន

# អារម្ភកថា

ឯកសារស្តីពីបំណិនផ្តល់ព័ត៌មានត្រឡប់ដែលបានចងក្រងឡើង គឺជាឯកសារជំនួយដល់លោកគ្រូ អ្នកគ្រូ ក្នុងការពង្រឹងគុណភាពបង្រៀន និងរៀន ជាពិសេសជួយកែលម្អកម្មសិក្សាការី ការិនី ក្នុងពេលចុះអនុវត្តកម្មសិក្សាគរុកោសល្យ ។ ឯកសារនេះបានចងក្រង និងកែសម្រួលដោយក្រុមការងាររបស់ ក្រសួងអប់រំ យុវជន និងកីឡា និងអង្គការ VVOB ព្រមទាំងមានអ្នកជំនួយការបច្ចេកទេស ពីសាកលវិទ្យាល័យ Artevelde ប្រទេសប៊ែលហ្ស៊ិក ។

ឯកសារនេះបានផ្តល់ព័ត៌មានជាមូលដ្ឋាន ស្តីពីបំណិនផ្តល់ព័ត៌មានត្រឡប់ ដែលមានសារៈសំខាន់សម្រាប់នាយក នាយករង នាយិកា នាយិការង គ្រូឧទ្ទេស និងគ្រូបង្រៀន នៅតាមសាលាគរុកោសល្យ និងវិក្រឹតការ និងមណ្ឌលកម្មសិក្សាគរុកោសល្យទាំងអស់ ប្រើប្រាស់ក្នុងពេលផ្តល់ព័ត៌មានត្រឡប់ដល់កម្មសិក្សាការី ការិនី ក្នុងពេលពួកគេអនុវត្តកម្មសិក្សាគរុកោសល្យ ។ បំណិននេះក៏អាចយក ទៅប្រើប្រាស់បានផងដែរ ក្នុងការផ្តល់ព័ត៌មានត្រឡប់ទៅដល់សហការីដទៃទៀត នៅតាមអង្គភាពនានា ។

ការអភិវឌ្ឍឯកសារត្រូវបានធ្វើឡើង ដោយផ្អែកលើលទ្ធផលចុះសង្កេតការផ្តល់ព័ត៌មានត្រឡប់ និងការបំពេញកម្រងសំណួរដោយគណៈគ្រប់គ្រង និងគ្រូឧទ្ទេសសាលាគរុកោសល្យ និងវិក្រឹតការរាជធានី ខេត្ត ។ លទ្ធផលនេះបានបង្ហាញឱ្យឃើញថា គ្រូឧទ្ទេស គ្រូប្រចាំថ្នាក់មានតម្រូវការអភិវឌ្ឍសមត្ថភាពបន្ថែម លើបំណិនផ្តល់ព័ត៌មានត្រឡប់ ។

ឆ្លៀតឱកាសនេះដែរ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ដែលបានលើកទឹកចិត្តដល់ក្រុមការងារក្នុងការបង្កើតស្នាដៃនេះ ។

គណៈកម្មការនិពន្ធយើងសង្ឃឹមថាឯកសារនេះនឹងក្លាយទៅជាអ្នកពិគ្រោះដ៏ល្អក្នុងការចូលរួមលើកកម្ពស់ការយល់ដឹងលើបំណិនផ្តល់ព័ត៌មានត្រឡប់របស់គ្រូឧទ្ទេស និងគ្រូប្រចាំថ្នាក់ ដែលជាមូលដ្ឋានធ្វើឱ្យការអនុវត្តកម្មសិក្សាគរុកោសល្យរបស់គរុសិស្សទទួលបានលទ្ធផលល្អ ដើម្បីក្លាយជាគ្រូបង្រៀនដែលមានសមត្ថភាពពេញលេញនាពេលអនាគត ។

យើងខ្ញុំរង់ចាំទទួលដោយក្តីសោមនស្សរីករាយរាល់ការកែលម្អពីសំណាក់លោកគ្រូ អ្នកគ្រូ និង ប្រិយមិត្តអ្នកអានទាំងអស់ ។

**គណៈកម្មការនិពន្ធ**

# គណៈកម្មការនិពន្ធ

## គណៈគ្រប់គ្រង

| | |
|---|---|
| ១. ឯកឧត្តម បណ្ឌិត ហង់ ជួនណារ៉ុន | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា |
| ២. ឯកឧត្តម បណ្ឌិត ណាត ប៊ុនរឿន | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |

## គណៈកម្មការត្រួតពិនិត្យ

| | |
|---|---|
| ១. លោក លាង សេងហាក់ | ប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
| ២. លោក ចាន់ សុភា | ប្រធាននាយកដ្ឋានបឋមសិក្សា |
| ៣. លោក សម សុភ័ក្តិ | អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
| ៤. លោក មួង ចាន់ទូច | ប្រធានការិយាល័យបណ្តុះបណ្តាល |

## គណៈកម្មការនិពន្ធ និងរៀបរៀង

| | |
|---|---|
| ១. លោក មួង ចាន់ទូច | ប្រធានការិយាល័យបណ្តុះបណ្តាល |
| ២. លោកស្រី ផន សុភា | អនុប្រធានការិយាល័យបណ្តុះបណ្តាល |
| ៣. លោក ងិន រិត | មន្ត្រីនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
| ៤. លោក ជា ផុន | ជំនួយការបច្ចេកទេស ក្រសួងអប់រំ យុវជន និងកីឡា |
| ៥. លោកអ៊ុង បូរិត | ប្រធានការិយាល័យបឋម មន្ទីរអ.យ.ក ខេត្តកំពង់ឆ្នាំង |
| ៦. លោក ឆិល ស៊ីថន | ប្រធានការិយាល័យបឋម មន្ទីរអ.យ.ក ខេត្តតាកែវ |
| ៧. លោក វ៉ូវ ផេងសែ | នាយកសាលាគរុកោសល្យ និងវិក្រឹតការរាជធានីភ្នំពេញ |
| ៨. លោក ហ៊ូ ភារិទ្ធ | នាយកសាលាគរុកោសល្យ និងវិក្រឹតការខេត្តកំពង់ឆ្នាំង |
| ៩. លោក ហង់ សំអឿន | នាយករងសាលាគរុកោសល្យ និងវិក្រឹតការខេត្តតាកែវ |
| ១០. លោកស្រី ស៊ឹម ស៊ីណាត | ប្រធានផ្នែកសិក្សា ស.គ.វ ខេត្តកំពង់ចាម |
| ១១. លោក ហង់ យ៉ន់ | អនុប្រធានផ្នែកសិក្សា ស.គ.វ ខេត្តកំពត |

## ជំនួយការបច្ចេកទេស និងចងក្រង

| | |
|---|---|
| ១. លោកស្រី Wanda Prins | ទីប្រឹក្សាផ្នែកអភិវឌ្ឍសមត្ថភាព អង្គការ VVOB |
| ២. លោក សយ សំផុន | អ្នកសម្របសម្រួលគម្រោង អង្គការ VVOB |
| ៣. កញ្ញា ង៉ែត សុខានី | ទីប្រឹក្សាអប់រំ អង្គការ VVOB |

# សេចក្តីផ្តើម

សព្វថ្ងៃនេះរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានយកចិត្តទុកដាក់កាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ រក្សាស្ថេរភាពសន្តិសុខសង្គម តាមរយៈកិច្ចប្រតិបត្តិការនៅក្នុងតំបន់ ពង្រឹងសន្តិភាព និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ។ ឆ្លើយតបនឹងបញ្ហានេះក្រសួងអប់រំ យុវជន និងកីឡា បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្លាក្នុងការកសាងធនធានមនុស្ស ប្រកបដោយគុណភាព និងសមត្ថភាព ។ កន្លងមកក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការងារជាច្រើនក្នុងការលើកកម្ពស់គុណភាពអប់រំ ដូចជាកំណែទម្រង់ប្រព័ន្ធអប់រំ ការកែលម្អកម្មវិធីសិក្សាចំណេះទូទៅ កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន និងបានបើកវគ្គបំប៉នសមត្ថភាពជាច្រើនដល់គ្រូបង្រៀន ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់សាលារៀននៅតាមមូលដ្ឋាន ។

ឯកសារបំណិនផ្តល់ព័ត៌មានត្រឡប់ត្រូវបានកសាងឡើង ដើម្បីរួមចំណែកក្នុងការពង្រឹងគុណភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀន និងការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន ។

## ១. ប្រវត្តិ និងការផ្តួចផ្តើម

ដោយផ្អែកទៅលើវិសាលភាពនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ និងផែនការសកម្មភាពនៃគោលនយោបាយស្តីពីគ្រូបង្រៀន ក្រសួងអប់រំ យុវជន និងកីឡាបានផ្តោតការយកចិត្តទុកដាក់លើគុណភាពគ្រូបង្រៀន ដែលជាកត្តាមួយមិនអាចខ្វះបាន ក្នុងការកែលម្អគុណភាពអប់រំ ហើយក៏បានធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការ VVOB ក្រោមជំនួយឥតសំណង ដើម្បីលើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀន ។

នៅឆ្នាំ២០១៤ ក្រសួងអប់រំ យុវជន និងកីឡា បានចុះអនុស្សារណៈជាមួយអង្គការ VVOB ដើម្បីធ្វើការងារនេះឱ្យមានប្រសិទ្ធភាព ព្រមទាំងបានបង្កើតក្រុមបច្ចេកទេសចំនួនបួនគឺ ក្រុមគណិតវិទ្យា ក្រុមវិទ្យាសាស្ត្រ ក្រុមកម្មសិក្សាគរុកោសល្យ និងក្រុមកសាងផែនការ ពិនិត្យតាមដាន និងវាយតម្លៃ ។ ក្រុមកម្មសិក្សាគរុកោសល្យបានផ្តោតការយកចិត្តទុកដាក់លើបំណិននៃការផ្តល់ព័ត៌មានត្រឡប់ ។

មុនដំណើរការអភិវឌ្ឍឯកសារក្រុមការងារបានធ្វើការស្រាវជ្រាវ ប្រមូល និងវិភាគព័ត៌មានអំពីការផ្តល់ព័ត៌មានត្រឡប់របស់សាលាគរុកោសល្យ និងវិក្រឹតការរាជធានី ខេត្តមួយចំនួន ។ តាមរយៈការវិភាគព័ត៌មាននេះ ក្រុមការងារបានរកឃើញថា គ្រូឧទ្ទេស និងគ្រូប្រចាំថ្នាក់ មានតម្រូវការបំណិនក្នុងការផ្តល់ព័ត៌មានត្រឡប់បន្ថែមទៀតដើម្បីកែលម្អប្រសិទ្ធភាពនៃការបង្រៀន និងរៀនរបស់គរុសិស្ស ។

## ២. គោលបំណង និងខ្លឹមសារនៃឯកសារបំណិនក្នុងការផ្តល់ព័ត៌មានត្រឡប់

### ២.១ គោលបំណង

ឯកសារបំណិនផ្តល់ព័ត៌មានត្រឡប់ត្រូវបានកសាងឡើងក្នុងគោលបំណង៖

- លើកកម្ពស់សមត្ថភាពរបស់គ្រូឧទ្ទេស និងគ្រូប្រចាំថ្នាក់ក្នុងការផ្តល់ព័ត៌មានត្រឡប់ដល់គរុសិស្ស
- លើកកម្ពស់ការយល់ដឹងរបស់កម្មសិក្សាការី ការិនី ក្នុងការបង្រៀន និងរៀន ជាពិសេសពេលធ្វើកម្មសិក្សាគរុកោសល្យ
- ជួយដល់គ្រូឧទ្ទេស និងគ្រូប្រចាំថ្នាក់ក្នុងការកែលម្អចំណុចខ្វះខាតរបស់កម្មសិក្សាការី ការិនី ក្នុងការបង្រៀន និងរៀន
- ជួយដល់គ្រូឧទ្ទេសនិងគ្រូប្រចាំថ្នាក់ក្នុងការវាយតម្លៃសកម្មភាពការងាររបស់កម្មសិក្សាការី ការិនី ឱ្យមានប្រសិទ្ធភាព និងគុណភាព
- ជួយពង្រឹងការអភិវឌ្ឍវិជ្ជាជីវៈរបស់កម្មសិក្សាការី ការិនី ។

### ២.២ ខ្លឹមសារ

ឯកសារនេះចែកចេញជា៤ផ្នែក៖

ផ្នែកទី១៖ លក្ខណសម្បត្តិ និង ភារកិច្ចរបស់គ្រូឧទ្ទេស និងគ្រូប្រចាំថ្នាក់

ផ្នែកទី២៖ ការផ្តល់ព័ត៌មានត្រឡប់

ផ្នែកទី៣៖ ជំហាននៃការផ្តល់ព័ត៌មានត្រឡប់

ផ្នែកទី៤៖ ការរៀបចំដំណើរការផ្តល់ព័ត៌មានត្រឡប់

# មាតិកា


**បុព្វកថា** ........ I

**អារម្ភកថា** ........ II

**គណៈកម្មការនិពន្ធ** ........ III

**សេចក្តីផ្តើម** ........ IV

**ផ្នែកទី ១៖ លក្ខណសម្បត្តិ និងភារកិច្ចរបស់គ្រូឧទ្ទេស និងគ្រូប្រចាំថ្នាក់** 1

១.១ លក្ខណសម្បត្តិរបស់គ្រូឧទ្ទេស និងគ្រូប្រចាំថ្នាក់ (គ្រូណែនាំ) ........ 2

១.២ ភារកិច្ចរបស់គ្រូឧទ្ទេស និងគ្រូប្រចាំថ្នាក់ក្នុងការដឹកនាំកម្មសិក្សាគរុកោសល្យ ........ 3

**ផ្នែកទី២៖ ការផ្តល់ព័ត៌មានត្រឡប់** 5

២.១ និយមន័យ ........ 6

២.២ គោលការណ៍ជាមូលដ្ឋាននៃការផ្តល់ព័ត៌មានត្រឡប់ ........ 6

២.៣. ទ្រឹស្តី Johari Window ........ 7

២.៤ មធ្យោបាយនៃការផ្តល់ព័ត៌មានត្រឡប់ ........ 9

២.៤.១ ការស្តាប់សកម្ម ........ 9

២.៤.២ កញ្ចក់ឆ្លុះបញ្ចាំង ........ 12

២.៤.៣ ការកែលម្អតាមបែបស្ថាបនា ........ 15

២.៤.៤. ការប្រើប្រាស់ "សារផ្តើមដោយពាក្យ ខ្ញុំ" ........ 18

**ផ្នែកទី ៣: ជំហាននៃការផ្តល់ព័ត៌មានត្រឡប់** 20

៣.១ ទិដ្ឋភាពទូទៅ ........ 21

៣.២ ជំហាននៃការផ្តល់ព័ត៌មានត្រឡប់ ........ 22

**ផ្នែកទី៤: ការរៀបចំផ្តល់ព័ត៌មានត្រឡប់** 30

៤.១ មុនពេលផ្តល់ព័ត៌មានត្រឡប់ ........ 31

៤.២ អំឡុងពេលផ្តល់ព័ត៌មានត្រឡប់ ........ 33

៤.៣ ក្រោយពេលផ្តល់ព័ត៌មានត្រឡប់ ......................................................................................33

ឧបសម្ព័ន្ធ ............................................................................................................................ 34

ឧបសម្ព័ន្ធ១៖ បញ្ជីសង្កេតសកម្មភាពនៃការស្តាប់សកម្ម ........................................................................ 35

ឧបសម្ព័ន្ធ២៖ ព្រឹត្តិបត្រសង្កេតសកម្មភាពផ្តល់ព័ត៌មានត្រឡប់ ............................................................... 36

ឯកសារយោង ....................................................................................................................... 39

# ផ្នែកទី១

# លក្ខណសម្បត្តិ និង ភារកិច្ចរបស់គ្រូឧទ្ទេស និងគ្រូប្រចាំថ្នាក់



# ផ្នែកទី ១៖ លក្ខណសម្បត្តិ និងភារកិច្ចរបស់គ្រូឧទ្ទេស និងគ្រូប្រចាំថ្នាក់

**គោលបំណង:** លើកកម្ពស់ការយល់ដឹងរបស់គ្រូឧទ្ទេស និងគ្រូប្រចាំថ្នាក់ក្នុងការរៀបចំខ្លួនដើម្បីដឹកនាំកម្មសិក្សាគរុកោសល្យឱ្យបានល្អប្រសើរ ។

## ១.១ លក្ខណសម្បត្តិរបស់គ្រូឧទ្ទេស និងគ្រូប្រចាំថ្នាក់ (គ្រូណែនាំ)

ដើម្បីឱ្យក្លាយជាគ្រូណែនាំល្អម្នាក់ ទាមទារឱ្យមានលក្ខណសម្បត្តិមួយចំនួនដូចខាងក្រោម៖

- **ធ្វើជាគំរូល្អ:** ជាមនុស្សដែលមានការគោរព ស្រឡាញ់ពីអ្នកដទៃ ដែលជាគំរូល្អដល់មនុស្សទូទៅ ជាពិសេសកម្មសិក្សាការី ការិនី ដោយស្តែងចេញតាមរយៈអាកប្បកិរិយា និងឥរិយាបថគំរូរបស់ខ្លួន។
- **ស្តាប់ដោយសកម្ម:** ស្តាប់ដោយយកចិត្តទុកដាក់ផ្តោតលើការប្រើប្រាស់ភាសាកាយវិការ និងភាសានិយាយ ។ គ្រូឧទ្ទេស ឬគ្រូប្រចាំថ្នាក់ដែលជាអ្នកស្តាប់សកម្ម ត្រូវចេះស្តាប់មតិអ្នកដទៃ និងស្វែងយល់ពីបញ្ហារបស់កម្មសិក្សាការី ការិនី ដោយយកចិត្តទុកដាក់និងផ្តល់ឱកាសឱ្យកម្មសិក្សាការី ការិនីគ្រប់គ្រាន់ ក្នុងការបញ្ចេញមតិយោបល់ ហើយមិនប្រញាប់ក្នុងការកាត់សេចក្តី ។
- **កំណត់បែបបទការងារបានច្បាស់លាស់:** គ្រូណែនាំត្រូវធានាថា កម្មសិក្សាការី ការិនីអនុវត្តបែបបទការងារ បានត្រឹមត្រូវតាមបទបញ្ញត្តិកម្មសិក្សាគរុកោសល្យ ។ នៅពេលកម្មសិក្សាការី ការិនីអនុវត្តការងារមិនបានល្អ ឬ បង្ហាញនូវឥរិយាបថមិនសមរម្យ ខណៈនោះគ្រូឧទ្ទេស ឬគ្រូប្រចាំថ្នាក់ត្រូវធ្វើការណែនាំឱ្យបានច្បាស់លាស់អំពីច្បាប់វិន័យ និងផែនការដែលកម្មសិក្សាការី ការិនីត្រូវអនុវត្ត ។
- **មានបំណិនក្នុងការវិភាគ:** ដើម្បីផ្តល់ព័ត៌មានត្រឡប់បែបស្ថាបនា ទៅដល់កម្មសិក្សាការី ការិនី គ្រូណែនាំ ត្រូវចេះធ្វើការវិភាគខ្លឹមសារមេរៀន និងឥរិយាបថរបស់កម្មសិក្សាការី ការិនី ព្រមទាំងផ្តល់ព័ត៌មានត្រឡប់ដោយភាពជាក់លាក់ និងស្មោះត្រង់ ។ ការផ្តល់ព័ត៌មានត្រឡប់ដោយភាពជាក់លាក់ និងស្មោះត្រង់អាចបង្កឱកាសឱ្យកម្មសិក្សាការី ការិនីមានការលូតលាស់ផ្នែកវិជ្ជាជីវៈរបស់ខ្លួនបានល្អ ។
- **មានការតាំងចិត្តក្នុងតួនាទីជាអ្នកផ្តល់ព័ត៌មានត្រឡប់:** គ្រូណែនាំត្រូវមានការតាំងចិត្តក្នុងការយកចិត្តទុកដាក់លើសុខុមាលភាព និងការអភិវឌ្ឍវិជ្ជាជីវៈរបស់កម្មសិក្សាការី ការិនី ហើយត្រូវធានាថា កម្មសិក្សាការី ការិនីអាចអភិវឌ្ឍសមត្ថភាពរបស់ខ្លួនបាន ក្នុងពេលអនុវត្តកម្មសិក្សាគរុកោសល្យ តាមរយៈការណែនាំ ឬផ្តល់ព័ត៌មានត្រឡប់របស់ខ្លួន ។

- **ទទួលយកកម្មសិក្សាការី ការិនីដោយពេញចិត្ត:** នៅពេលដែលគ្រូណែនាំបង្ហាញការយកចិត្តទុកដាក់ទៅកាន់កម្មសិក្សាការី ការិនី វាអាចបង្កើតនូវបរិយាកាសកក់ក្ដៅដល់គរុសិស្ស ដែលធ្វើឱ្យពួកគេអាចរៀនសូត្រពីគ្រូណែនាំបានច្រើន ។

- **មានបំណិនគាំទ្រផ្នែកគរុកោសល្យ:** គ្រូណែនាំគឺជាគ្រូដែលមានបទពិសោធន៍ និងមានឆន្ទៈក្នុងការចែករំលែកពីអ្វីដែលខ្លួនបានដឹងដល់អ្នកដទៃ ។

- **ធ្វើជាគំរូជាអ្នករៀនពេញមួយជីវិត:** គ្រូណែនាំបង្ហាញថា ខ្លួនជាអ្នកដែលមានចំណង់ចំណូលចិត្តក្នុងការរៀនសូត្របន្ត ដើម្បីអភិវឌ្ឍសមត្ថភាពរបស់ខ្លួន និងចេះឆ្លុះបញ្ចាំងដំណើរការបង្រៀនរបស់ខ្លួនឱ្យបានល្អប្រសើរជាប្រចាំ ។

- **ផ្ដល់ក្ដីសង្ឃឹម និងគំនិតសុទិដ្ឋិនិយម:** គ្រូណែនាំត្រូវមានទំនាក់ទំនង ជាមួយកម្មសិក្សាការី ការិនីប្រកបដោយក្ដីសង្ឃឹម និងការលើកទឹកចិត្តដើម្បីឱ្យពួកគេមានការអភិវឌ្ឍចំណេះដឹងវិជ្ជាជីវៈ ។

## ១.២ ភារកិច្ចរបស់គ្រូឧទ្ទេស និងគ្រូប្រចាំថ្នាក់ក្នុងការដឹកនាំកម្មសិក្សាគរុកោសល្យ

### ក. ភារកិច្ចរបស់គ្រូឧទ្ទេស

- ចូលរួមដឹកនាំ និងគ្រប់គ្រងកម្មសិក្សាការី ការិនីទៅកាន់មណ្ឌលកម្មសិក្សាគរុកោសល្យ
- មានវត្តមាននៅមណ្ឌលកម្មសិក្សា ដែលខ្លួនទទួលខុសត្រូវ និងចូលរួមប្រជុំឱ្យបានទៀងទាត់ជាមួយគណៈកម្មការថ្នាក់សាលារៀន និងកម្មសិក្សាការី ការិនីរៀងរាល់សប្ដាហ៍ ព្រមទាំងបង្ហាញពីចំណុចខ្លាំង និងចំណុចត្រូវកែលម្អរបស់កម្មសិក្សាការី ការិនីម្នាក់ៗ ដើម្បីមានវិធានការលើកទឹកចិត្ត និងកែលម្អទាន់ពេលវេលា
- សហការយ៉ាងជិតស្និទ្ធជាមួយប្រធានក្រុមដឹកនាំ គ្រូប្រចាំថ្នាក់ ឬគ្រូបង្រៀនតាមមុខវិជ្ជា ដើម្បីតាមដាន និងកែលម្អកម្មសិក្សាការី ការិនីឱ្យបានទាន់ពេលវេលា
- តាមដានការបង្រៀន និងរៀន និងផ្ដល់ព័ត៌មានត្រឡប់ដល់កម្មសិក្សាការី ការិនី
- សហការជាមួយគ្រូប្រចាំថ្នាក់ ដើម្បីដាក់ពិន្ទុ និងមូលវិចារណ៍លើព្រឹត្តិបត្រវាយតម្លៃឱ្យបានត្រឹមត្រូវ
- ធ្វើសេចក្ដីព្រាងតារាងពិន្ទុ និងលទ្ធផលកម្មសិក្សាគរុកោសល្យ រួចបញ្ជូនទៅគណៈកម្មការដឹកនាំកម្មសិក្សាគរុកោសល្យថ្នាក់សាលារៀន។

### ខ. ភារកិច្ចរបស់គ្រូប្រចាំថ្នាក់

- សហការជិតស្និទ្ធជាមួយគ្រូឧទ្ទេសប្រចាំមណ្ឌលកម្មសិក្សាដែលចូលរួមដឹកនាំកម្មសិក្សាគរុកោសល្យពិសេសលើការងារដាក់ពិន្ទុនិងដាក់មូលវិចារណ៍លើព្រឹត្តិបត្រវាយតម្លៃឱ្យបានត្រឹមត្រូវ និងសមស្រប

- រៀបរាប់ប្រាប់កម្មសិក្សាការី ការិនី ពីរបៀបរបបការងារ ទំនៀមទម្លាប់ផ្សេងៗរបស់សាលារៀនព្រមទាំងណែនាំកម្មសិក្សាការី ការិនីឱ្យស្គាល់ និងមានទំនាក់ទំនងល្អជាមួយបុគ្គលិកទាំងអស់ក្នុងសាលារៀន
- តាមដានការបង្រៀន និងរៀន និងផ្តល់ព័ត៌មានត្រឡប់ដល់កម្មសិក្សាការី ការិនី
- របៀបធ្វើទំនាក់ទំនងជាមួយសិស្ស និងជាមួយសហគមន៍ក្នុង និងក្រៅសាលារៀន
- ផ្តល់ព័ត៌មានសំខាន់ៗ ដែលពាក់ព័ន្ធនឹងលក្ខណៈពិសេសរបស់ថ្នាក់រៀន និងសាលារៀន ជាពិសេសលក្ខណៈនៃការសិក្សា និងឥរិយាបថរបស់សិស្សក្នុងថ្នាក់ និងក្នុងសាលារៀនទាំងមូល
- យកអស់កម្លាំងកាយចិត្តដើម្បីជួយកម្មសិក្សាការី ការិនី អំពី៖
  - របៀបគ្រប់គ្រង និងរដ្ឋបាលថ្នាក់រៀន
  - ការងារបង្រៀននិងរៀន (ការធ្វើផែនការបង្រៀន ការរៀបចំកិច្ចតែងការបង្រៀន ការឡើងបង្រៀន ឥរិយាបថចំពោះមុខសិស្ស ...) ។

# ផ្នែកទី២

## ការផ្តល់ព័ត៌មានត្រឡប់





# ផ្នែកទី២៖ ការផ្ដល់ព័ត៌មានត្រឡប់

**គោលបំណង:** បង្ហាញពីបច្ចេកទេសដល់គ្រូឧទ្ទេស និងគ្រូប្រចាំថ្នាក់ ដើម្បីផ្ដល់ព័ត៌មានត្រឡប់ប្រកបដោយប្រសិទ្ធភាព ។

## ២.១ និយមន័យ

- ការផ្ដល់ព័ត៌មានត្រឡប់ គឺការទទួលស្គាល់ភាពវិជ្ជមាននៃការងារដែលគរុសិស្ស ឬកម្មសិក្សាការី ការិនី អនុវត្តបានល្អ ឬការកែលម្អតាមបែបស្ថាបនាទៅលើបំណិន ឬកិច្ចការដែលបំពេញមិនទាន់បានល្អ ។
- ការផ្ដល់ព័ត៌មានត្រឡប់ គឺជាការផ្ដល់ឱ្យនូវចំណុចល្អ ចំណុចខ្វះខាត និងអនុសាសន៍ ដោយគ្រូណែនាំ (គ្រូប្រចាំថ្នាក់ ឬគ្រូឧទ្ទេស) អំពីទិដ្ឋភាពនៃការអនុវត្តការងារ ឬការយល់ដឹងរបស់អ្នកណាម្នាក់ (កម្មសិក្សាការី ការិនី ) ។
- ការផ្ដល់ព័ត៌មានត្រឡប់ គឺជាការផ្ដល់នូវព័ត៌មានជាក់លាក់អំពីឥរិយាបថរបស់នរណាម្នាក់ដើម្បីឱ្យដឹងថាគួរបន្តរក្សាឥរិយាបថមិនល្អ ឬក៏ត្រូវផ្លាស់ប្ដូរចេញ ។

ការផ្ដល់ព័ត៌មានត្រឡប់ជាទូទៅកើតឡើងបន្ទាប់ពីសង្កេតការបង្រៀន ប៉ុន្តែក៏អាចផ្ដល់ព័ត៌មានត្រឡប់បានបន្ទាប់ពីសកម្មភាព ឬឥរិយាបថក្រៅម៉ោងបង្រៀន ក្នុងស្ថានភាពណាមួយដែលតម្រូវឱ្យ ។

## ២.២ គោលការណ៍ជាមូលដ្ឋាននៃការផ្ដល់ព័ត៌មានត្រឡប់

យោងតាមលោក Portner[1], ២០០៣ ការផ្ដល់ព័ត៌មានត្រឡប់ត្រូវគោរពគោលការណ៍ដូចខាងក្រោម៖

- គោរពគ្នាទៅវិញទៅមក ទាំងពាក្យសម្ដី និងសកម្មភាព
- និយាយក្នុងនាមខ្លួនយើងផ្ទាល់ជាអ្នកផ្ដល់ព័ត៌មានត្រឡប់ដោយជាក់លាក់ និងស្មោះត្រង់
- និយាយពីអ្វីដែលកើតឡើងក្នុងពេលបច្ចុប្បន្ន (ការបង្រៀនថ្មីៗ) មិននិយាយពីអ្វីដែលបានកើតឡើងតាំងពីយូរមកហើយនោះទេ
- រក្សាទុកជាការសម្ងាត់នូវអ្វីដែលបានពិភាក្សា គឺសម្រាប់តែអ្នកផ្ដល់ព័ត៌មានត្រឡប់ និងកម្មសិក្សាការីការិនីប៉ុណ្ណោះ
- យកចិត្តទុកដាក់ខ្លាំង លើការរៀនសូត្រជាមួយគ្នាអំពីការបង្រៀន និងរៀន ។

[1] Hal Portner, author of “mentoring new teachers”, USA 2003:

## ២.៣. ទ្រឹស្តី Johari Window[2]

ពាក្យថា " Johari Window " ត្រូវបានបង្កើតឡើងដោយអ្នកចិត្តវិទ្យាជនជាតិអាមេរិកពីរនាក់គឺលោក Joseph Luft និង Hari Ingham ។ តាមទ្រឹស្តី Johari Window កាលណាតំបន់បើកចំហកាន់តែធំ វាធ្វើឱ្យអ្នកស្គាល់ខ្លួនឯងកាន់តែច្បាស់ ។ Johari បានចែកជា៤តំបន់ ដែលតំបន់នីមួយៗតំណាងឱ្យបុគ្គលិកលក្ខណៈរបស់មនុស្សម្នាក់ៗ ។ តំបន់ទាំងនោះបង្ហាញអំពីបុគ្គលិកលក្ខណៈរបស់យើងដែលដឹង ឬមិនដឹងដោយខ្លួនឯង ឬដោយអ្នកដទៃទៀត ។ ដើម្បីស្គាល់ខ្លួនឯងឱ្យកាន់តែច្បាស់ អ្នកត្រូវដឹងថាតើអ្នកដទៃមើលមកអ្នកជាមនុស្សបែបណា ។

គំនូសតាងទ្រឹស្តី Johari Window បង្ហាញអំពីគំរូសម្រាប់ការយល់ដឹងអំពីខ្លួនឯង ការអភិវឌ្ឍខ្លួន ការអភិវឌ្ឍជាក្រុម និងការយល់ដឹងពីការប្រាស្រ័យទាក់ទងគ្នារវាងខ្លួនឯង ជាមួយអ្នកដទៃ ដូចខាងក្រោម៖

| ទ្រឹស្តី Johari Window | | ----------------ផ្តល់ព័ត៌មានត្រឡប់------------ → | |
|---|---|---|---|
| | | ខ្លួនឯងដឹង | ខ្លួនឯងមិនដឹង |
| ← --- ផ្តល់ព័ត៌មានត្រឡប់ --- | អ្នកដទៃដឹង | ១. តំបន់បើកចំហ | ២. តំបន់ងងឹត |
| | អ្នកដទៃមិនដឹង | ៣. តំបន់បិទបាំង | ៤. តំបន់មិនដឹង |

### ១. តំបន់បើកចំហ

តំបន់នេះតំណាងឱ្យអ្វីដែលយើងដឹងពីខ្លួនឯង និងអ្វីដែលអ្នកដទៃ ដឹងពីខ្លួនយើងរួមមាន៖ ឥរិយាបថ ចំណេះដឹង និងបំណិន ។

ឧទាហរណ៍៖

*"ខ្ញុំដឹងថាខ្ញុំនិយាយលឿន អ្នកដទៃក៏ស្តាប់ឮបែបនេះដែរ ដូចនេះពួកគេដឹងថាខ្ញុំនិយាយលឿន"។*

### ២. តំបន់ងងឹត

តំបន់នេះបង្ហាញអ្វីៗដែលយើងមិនអាចដឹងពីខ្លួនឯង ប៉ុន្តែអ្នកដទៃដឹង ឬមើលឃើញ ។

[2] Johari Window: “A graphic model of interpersonal awareness”, Joseph Luft en Hari Ingham USA

ឧទាហរណ៍៖

*ខ្ញុំបានរៀបចំកិច្ចតែងការបង្រៀនមេរៀនគណិតវិទ្យា ហើយបានដាក់ឱ្យគ្រូណែនាំរបស់ខ្ញុំពិនិត្យ បន្ទាប់ពីគាត់បានពិនិត្យកិច្ចតែងការបង្រៀនរបស់ខ្ញុំរួច គាត់ឃើញថាខ្ញុំប្រើរូបមន្តខុស ។ គាត់បានពន្យល់ និងកែកិច្ចតែងការរបស់ខ្ញុំ ។ ការពន្យល់របស់គាត់បានជួយឱ្យខ្ញុំមើលឃើញកំហុស ដែលខ្ញុំមិនអាចដឹងដោយខ្លួនឯង ។*

### ៣. តំបន់ដែលបិទបាំង

តំបន់នេះបង្ហាញពីអ្វីដែលយើងដឹងអំពីខ្លួនឯង ប៉ុន្តែអ្នកដទៃមិនបានដឹងអំពីខ្លួនយើងទេ ពីព្រោះយើងរក្សាវាទុកជាអាថ៌កំបាំង ។

ឧទាហរណ៍៖

- *ខ្ញុំដឹងថាខ្ញុំជាមនុស្សចូលចិត្តច្រណែន ប៉ុន្តែខ្ញុំមិនបង្ហាញឱ្យអ្នកដទៃដឹងទេ ។*
- *ខ្ញុំពូកែផ្នែកព័ត៌មានវិទ្យា ប៉ុន្តែខ្ញុំមិនដែលបង្ហាញដល់ក្រុមការងាររបស់ខ្ញុំឱ្យដឹងទេ ។*
- *ខ្ញុំជាមនុស្សដែលមិនសូវមានទំនុកចិត្តលើខ្លួនឯងប៉ុន្តែខ្ញុំព្យាយាមមិនបង្ហាញវានោះទេ ហើយព្យាយាមធ្វើជាមនុស្សដែលមានភាពជឿជាក់ខ្លាំង ។*

ភាពស្និទ្ធស្នាល និងទំនាក់ទំនងល្អ ធ្វើឱ្យខ្ញុំមានភាពរីករាយក្នុងការចែករំលែកចំណេះដឹង ឬបញ្ហាផ្ទាល់ខ្លួនរបស់ខ្ញុំដល់អ្នកដទៃ ។ វាធ្វើឱ្យតំបន់បិទបាំងរបស់ខ្ញុំរួមតូច និងពង្រីកតំបន់បើកចំហរបស់ខ្ញុំឱ្យកាន់តែធំ ។ វាធ្វើឱ្យអ្នកដទៃបានដឹង ឬស្គាល់ពីខ្ញុំកាន់តែច្បាស់ ប៉ុន្តែមិនមែនគ្រប់រឿងត្រូវតែចែករំលែកឱ្យគេដឹងនោះទេ ។ មានរឿងខ្លះយើងអាចរក្សាវាជាអាថ៌កំបាំង មិនឱ្យអ្នកដទៃដឹង ។

### ៤. តំបន់មិនដឹង

គឺជាតំបន់ដែលបង្ហាញពីបុគ្គលិកលក្ខណៈរបស់យើង ដែលយើងអាចមិនដឹង ឬមើលមិនឃើញដោយខ្លួនឯង ហើយអ្នកដទៃក៏មិនដឹងពីខ្លួនយើង ពីព្រោះវាអាចជាបញ្ហាផ្លូវចិត្ត ឬចិត្តសាស្ត្រ ។

ឧទាហរណ៍៖

*ខ្ញុំមានការពិបាកក្នុងការទំនាក់ទំនងជាមួយអ្នកដទៃនិងមិនដឹងពីមូលហេតុដែលបណ្ដាលឱ្យបញ្ហានេះកើតឡើង ។ អ្នកដទៃមើលមកខ្ញុំ ក៏មិនដឹងថាខ្ញុំមានបញ្ហានេះដែរ ។ ខ្ញុំបានធ្វើការប្រឹក្សាជាមួយអ្នកជំនាញផ្នែកចិត្តសាស្ត្រ ហើយខ្ញុំក៏ចាប់ផ្ដើមនិយាយប្រាប់អំពីរឿងរ៉ាវអតីតកាលរបស់ខ្ញុំដែលខ្ញុំធ្លាប់បានទុកចិត្តមនុស្សខុស ដែលជាហេតុធ្វើឱ្យខ្ញុំលែងជឿទុកចិត្តអ្នកដទៃ ។ រហូតមកដល់ពេលនេះ ខ្ញុំមិនដែលគិតថារឿងរ៉ាវអតីតកាលរបស់ខ្ញុំ ជាកត្តាដែលធ្វើឱ្យខ្ញុំមានការលំបាកក្នុងការធ្វើទំនាក់ទំនងជាមួយអ្នកដទៃនោះទេ ។ តាមរយៈការជជែកពិភាក្សារបស់ខ្ញុំជាមួយអ្នកចិត្តសាស្ត្រ ខ្ញុំចាប់ផ្ដើមដឹងពីមូលហេតុទាំងនោះ ដែលពីមុនខ្ញុំមិនបានដឹងសោះ ។ ក្រោយមកខ្ញុំអាចជ្រើសរើសយកបញ្ហាដែលធ្លាប់កើតមាននៅតំបន់មិនដឹងទៅដាក់ក្នុងតំបន់បិទបាំង ឬតំបន់បើកចំហវិញ ។*

# សន្និដ្ឋាន

ការផ្តល់ព័ត៌មានត្រឡប់ត្រូវធ្វើយ៉ាងណាជួយឱ្យតំបន់បើកចំហឱ្យរីកកាន់តែធំ ។ មានវិធីផ្សេងៗដែលអាចធ្វើឱ្យតំបន់នេះរីកធំ តាមរយៈការសង្កេត និងផ្តល់ព័ត៌មានត្រឡប់របស់អ្នកដទៃ (ដែលធ្វើឱ្យតំបន់ងងឹតរួមតូច) និងការទម្លាយរឿងអាថ៌កំបាំងរបស់ខ្លួន (ដែលធ្វើឱ្យតំបន់បិទបាំងរួមតូច) ។

តំបន់បើកចំហគឺជាតំបន់ដែលសំខាន់ជាងគេ ជាទូទៅនៅពេលដែលយើងស្គាល់គ្នាកាន់តែច្បាស់ យើងនឹងមានកិច្ចសហការជាមួយគ្នាកាន់តែមានប្រសិទ្ធភាព និងទទួលបានលទ្ធផលខ្ពស់ ។ គោលដៅចម្បងរបស់ទ្រឹស្តី Johari គឺដើម្បីពង្រីកតំបន់បើកចំហឱ្យធំជាងមុន ។ ការផ្លាស់ប្តូររវាងតំបន់បើកចំហ តំបន់ងងឹត និងតំបន់បិទបាំង អាចជួយឱ្យយើងយល់កាន់តែស៊ីជម្រៅ ពីដំណើរការនៃការឆ្លុះបញ្ចាំង ។

តាមការពន្យល់ពីទ្រឹស្តី Johari ខាងលើ យើងអាចដឹងបានថា តើហេតុអ្វីបានជាវាមានប្រយោជន៍សម្រាប់គរុសិស្សក្នុងការធ្វើការឆ្លុះបញ្ចាំងលើការងាររបស់ខ្លួន តាមរយៈការសន្ទនាជាមួយអ្នកដទៃ ដូចជាគ្រូប្រចាំថ្នាក់ គ្រូមុខវិជ្ជា និងគ្រូឧទ្ទេសជាដើម ។ អ្នកដទៃប្រហែលជាមានទស្សនៈខុសពីអ្វី ដែលគរុសិស្សម្នាក់ៗមានចំពោះខ្លួនឯង ។ ជាការពិតណាស់តំបន់ងងឹតរបស់គរុសិស្សត្រូវតែធ្វើឱ្យរួមតូច ដែលធ្វើឱ្យគរុសិស្សមានគំនិតច្រើនបន្ថែមទៀតក្នុងការធ្វើឱ្យសម្រេចបានលទ្ធផលខ្ពស់ ។ ពេលនោះគរុសិស្ស នឹងយល់ដឹងពីខ្លួនឯងកាន់តែច្បាស់បន្តិចម្តងៗ ក្នុងនាមជាមនុស្សម្នាក់ និងជាគ្រូបង្រៀនម្នាក់។

## ២.៤ មធ្យោបាយនៃការផ្តល់ព័ត៌មានត្រឡប់

មធ្យោបាយនៃការផ្តល់ព័ត៌មានត្រឡប់មាន៖

- ការស្តាប់ដោយសកម្ម
- ការប្រើកញ្ចក់ឆ្លុះបញ្ចាំង
- ការកែលម្អតាមបែបស្ថាបនា
- ការប្រើសារដោយផ្តើមពីពាក្យខ្ញុំ

### ២.៤.១ ការស្តាប់សកម្ម

DVDបំណិនព័ត៌មានត្រឡប់

- វីដេអូទី១៖ បង្ហាញពីការស្តាប់ដោយមិនសកម្ម
- វីដេអូទី២៖ បង្ហាញពីការការស្តាប់ដោយសកម្ម

ការស្តាប់សកម្ម គឺជាបំណិនស្តាប់ដើម្បីបង្កើនការយល់ដឹង និងទំនាក់ទំនងល្អរវាងអ្នកស្តាប់ និងអ្នកនិយាយ ។ អ្នកស្តាប់សកម្មត្រូវយកចិត្តទុកដាក់ស្តាប់អ្នកនិយាយឱ្យបានល្អទាំងភាសានិយាយ និងភាសាកាយវិការ បន្ទាប់មកសង្ខេប ឬនិយាយឡើងវិញនូវចំណុចសំខាន់ៗ នៃសាររបស់អ្នកនិយាយ ។

### ការស្តាប់សកម្មមានន័យថាៈ

- ***យល់***
  តើសាររបស់កម្មសិក្សាការី ការិនី បានប្រាប់ខ្ញុំអ្វីខ្លះ?

- ***សង្កេតឥរិយាបថ (អារម្មណ៍របស់ដៃគូ)***
  តើកម្មសិក្សាការី ការិនី មានអារម្មណ៍ដូចម្តេចពេលកំពុងសន្ទនាគ្នា? *ធុញថប់ ព្រួយបារម្ភ សប្បាយចិត្ត ឬមានទំនុកចិត្ត?* តើអារម្មណ៍ទាំងនេះ អាចជះឥទ្ធិពលដល់ការអនុវត្តការងាររបស់កម្មសិក្សាការី ការិនី ដែរឬទេ?

- ***គិត***
  តើខ្ញុំសង្កេត ឬកត់សម្គាល់ឃើញអ្វីខ្លះនៅពេលដែលកម្មសិក្សាការី ការិនី កំពុងនិយាយ?

- ***ដឹង (ឆាប់ដឹងសាច់រឿង)***
  តើមានរឿងអ្វី ដែលកម្មសិក្សាការី ការិនី ចង់និយាយ ប៉ុន្តែខ្លាចមិនហ៊ាននិយាយ?
  តើខ្ញុំត្រូវធ្វើដូចម្តេច ដើម្បីឱ្យកម្មសិក្សាការី ការិនី មានភាពក្លាហានក្នុងការពិភាក្សាគ្នា?

### ២.៤.១.១ អត្ថប្រយោជន៍នៃការស្តាប់សកម្ម

- លើកទឹកចិត្តអ្នកនិយាយ
- លើកកម្ពស់ការទុកចិត្ត និងការគោរពគ្នាទៅវិញទៅមក
- ជួយឱ្យអ្នកស្តាប់ទទួលព័ត៌មានបានល្អ និងគ្រប់ជ្រុងជ្រោយ
- លើកកម្ពស់ទំនាក់ទំនង
- ដោះស្រាយបញ្ហាបានកាន់តែប្រសើរ
- ទទួលបានការសហការល្អ
- លើកកម្ពស់ការយល់ចិត្តគ្នា ។

### ២.៤.១.២ គោលការណ៍នៃការស្តាប់សកម្ម

ដើម្បីឱ្យការស្តាប់សកម្មមានប្រសិទ្ធភាព អ្នកស្តាប់ត្រូវ៖

#### ១. យកចិត្តទុកដាក់ស្តាប់

- សម្លឹងមើលទៅកាន់អ្នកនិយាយ
- ចៀសវាងមិនឱ្យមានការរំខានពីកត្តាផ្សេងៗដូចជាការនិយាយទូរស័ព្ទការដើរចេញចូលរបស់សិស្ស ឬក្រុមការងារ
- សង្កេតមើល "ភាសាកាយវិការ" របស់អ្នកនិយាយ ។

#### ២. ប្រើឥរិយាបថកំពុងស្តាប់

- ញញឹម ឬបង្ហាញទឹកមុខរីករាយ
- បើកចិត្តឱ្យទូលាយដើម្បីទទួលយកព័ត៌មាន
- អង្គុយឱ្យបានសមរម្យ
- ផ្តោតអារម្មណ៍ និងយល់ពីចិត្តរបស់អ្នកនិយាយ
- ប្រើក្រសែភ្នែក
- ងក់ក្បាលម្តងម្កាល
- លើកទឹកចិត្តអ្នកនិយាយតាមរយៈការនិយាយៈ ចាស៎ ឬ បាទ អូ ពិតមែនឬ...

#### ៣. សង្ខេប និងសួរសំណួរបញ្ជាក់

- និយាយសង្ខេប "អ្វីដែលខ្ញុំបានស្តាប់ឮគឺ..." ឬ "ស្តាប់ទៅហាក់ដូចជាអ្នកចង់និយាយថា..."
- សួរសំណួរបញ្ជាក់ដូចជាៈ "តើអ្នកចង់មានន័យដូចម្តេចនៅពេលដែលអ្នកនិយាយថា...?"

#### ៤. ចៀសវាងបុរេវិនិច្ឆ័យ

- កុំនិយាយកាត់សម្តី
- ស្តាប់គេនិយាយ ជាជាងធ្វើការវិនិច្ឆ័យ (ចូរប្រុងប្រយ័ត្នចំពោះការវិនិច្ឆ័យរបស់អ្នក!)
- ទុកពេលឱ្យគេនិយាយឱ្យចប់

#### ៥. ឆ្លើយតបឱ្យបានសមរម្យ

- មិនលាក់លៀម បើកចិត្តឱ្យទូលាយ និងស្មោះត្រង់ចំពោះការឆ្លើយតបរបស់អ្នក
- បញ្ចូលគំនិតរបស់អ្នកដោយការគោរព
- ស្វែងយល់ពីស្ថានភាពរបស់អ្នកនិយាយ

### ចំណុចគួរចៀសវាង

មានចំណុចមួយចំនួនដែលអ្នកផ្ដល់ព័ត៌មានត្រឡប់មិនគួរធ្វើ៖



- ខ្វះការយកចិត្តទុកដាក់ទៅលើអារម្មណ៍ និងមនោសញ្ចេតនារបស់កម្មសិក្សាការី ការិនី
- ធ្វើសេចក្ដីសន្និដ្ឋាន និងវិនិច្ឆ័យដោយប្រញាប់ប្រញាល់ ដើរតួជាអ្នកចិត្តសាស្ត្រ ឬក៏ជជីកសួររឿងផ្ទាល់ខ្លួនខ្លាំងពេក
- ស្វែងរកតែកំហុស
- បដិសេធចោលរាល់បញ្ហាដែលគេលើកឡើង
- ផ្ដល់ការបកស្រាយផ្ទាល់ខ្លួន ដោយមិនផ្ដល់ឱកាសឱ្យកម្មសិក្សាការី ការិនី ពន្យល់ពីមូលហេតុរបស់គេ
- លើកយករឿងផ្ទាល់ខ្លួនមកនិយាយ ហើយឈប់ស្ដាប់ការបកស្រាយរបស់គេ
- ធ្វើការចោទសួរដេញដោល
- ផ្ដល់ជាដំណោះស្រាយនិងដំបូន្មានច្រើនពេក ផ្ទុយទៅវិញគ្រូណែនាំគួរលើកទឹកចិត្តឱ្យកម្មសិក្សាការី ការិនីចេះគិតពីដំណោះស្រាយដោយខ្លួនឯង
- ធ្វើការវិនិច្ឆ័យដោយលម្អៀង ។ ឧទាហរណ៍ៈ គ្រូណែនាំមិនចូលចិត្តកម្មសិក្សាការី ការិនីម្នាក់ហ្នឹង ដោយសារតែកម្មសិក្សាការី ការិនីនោះធ្លាប់ធ្វើឱ្យគាត់ខឹង ដែលជាហេតុគ្រូណែនាំចាប់ផ្ដើមសង្កេតមើលមកកម្មសិក្សាការី ការិនីឃើញតែចំណុចអវិជ្ជមាន ។

### ២.៤.២ កញ្ចក់ឆ្លុះបញ្ចាំង

"កញ្ចក់ឆ្លុះបញ្ចាំង" ជាវិធីដ៏មានប្រសិទ្ធភាពមួយក្នុងការផ្ដល់ព័ត៌មានត្រឡប់ ។ វាដូចជាការដាក់កញ្ចក់នៅពីមុខនរណាម្នាក់ ដូចនេះគេអាចធ្វើការឆ្លុះបញ្ចាំងពីឥរិយាបថរបស់ខ្លួនបាន ។ គ្រូណែនាំជួយកម្មសិក្សាការី ការិនី ឱ្យចេះឆ្លុះបញ្ចាំងពីសកម្មភាពរបស់ខ្លួនឡើងវិញនូវអ្វីដែលកម្មសិក្សាការី ការិនីបានធ្វើ ឬប្រព្រឹត្តកន្លងមកដោយប្រាប់នូវអ្វីដែលគ្រូណែនាំបានសង្កេតឃើញ ។



គ្រូណែនាំអាចប្រើវិធីផ្សេងៗក្នុងការធ្វើការឆ្លុះបញ្ចាំងដូចខាងក្រោម៖

- **និយាយតាម**

គឺជាការនិយាយតាម (ថាតាម) នូវចំណុចសំខាន់ៗដែលកម្មសិក្សាការី ការិនីបានលើកឡើង រួចសួរជាសំណួរ ។

ឧទាហរណ៍ៈ "អ្នកបាននិយាយថាការគ្រប់គ្រងថ្នាក់រៀនគឺជាការងារសំខាន់ ។ តើអ្នកមានផែនការធ្វើការគ្រប់គ្រងថ្នាក់រៀនដោយរបៀបណា?"

- **និយាយបញ្ជាក់**

គឺជាការនិយាយបញ្ជាក់ឡើងវិញនូវមតិយោបល់របស់កម្មសិក្សាការី ការិនី ។ វាអាចជួយកម្មសិក្សាការី ការិនី ឱ្យចេះឆ្លុះបញ្ចាំងបន្ថែមទៀត និងធ្វើឱ្យមានគំនិតកាន់តែច្រើនក្នុងដំណើរការឆ្លុះបញ្ចាំង ។

ឧទាហរណ៍: កម្មសិក្សាការី ការិនី បាននិយាយថា: "ខ្ញុំមានអារម្មណ៍ថាថ្ងៃនេះ ខ្ញុំគ្រប់គ្រងថ្នាក់រៀន មិនបានល្អទេព្រោះសិស្សមិនបានយកចិត្តទុកដាក់ស្ដាប់សោះនៅពេលដែលខ្ញុំពន្យល់" ។ គ្រូប្រចាំថ្នាក់អាចនិយាយបញ្ជាក់ឡើងវិញថា: "អញ្ចឹងប្អូននិយាយថាប្អូនចង់ឱ្យសិស្សបានចូលរួមសកម្មជាងនេះបន្ថែមទៀតនៅថ្ងៃនេះ!" ។

- **និយាយសង្ខេប**

គឺជាការនិយាយសង្ខេបពីការសន្ទនា ឬសកម្មភាពដែលបានធ្វើ ។

ឧទាហរណ៍: កម្មសិក្សាការី ការិនីបានប្រាប់គ្រូណែនាំយ៉ាងលម្អិត អំពីបញ្ហាដែលបានកើតឡើងនៅក្នុងថ្នាក់ជាមួយនឹងសិស្សម្នាក់ឈ្មោះ**សុភាព** ។ គ្រូណែនាំនិយាយសង្ខេប " ប្អូនបាននិយាយថាប្អូនមិនសប្បាយចិត្តជាមួយ**សុភាព** ដោយសារសិស្សម្នាក់នេះមានឥរិយាបថមិនសមរម្យ ។ ប្អូនក៏បាននិយាយជាមួយសុភាពរួចហើយ ឥឡូវនេះប្អូនឈប់ខឹងពីអ្វីដែលបានកើតឡើង ក៏ប៉ុន្តែនៅតែបារម្ភពីឥរិយាបថរបស់គាត់នាពេលអនាគត " ។

**កញ្ចក់ឆ្លុះបញ្ចាំងមានបីប្រភេទ៖**

សកម្មភាពឆ្លើយតបខាងលើអាចអនុវត្តបានតាមមធ្យោបាយផ្សេងៗគ្នា ។ គ្រូណែនាំអាចជ្រើសរើសការឆ្លុះបញ្ចាំងទៅលើអារម្មណ៍របស់កម្មសិក្សាការី ការិនី (**<u>កញ្ចក់កក់ក្ដៅ</u>**) ឬការឆ្លុះបញ្ចាំងទៅលើភាពជាក់ស្ដែង និងខ្លឹមសារ (**<u>កញ្ចក់ត្រជាក់</u>**) ឬការឆ្លុះបញ្ចាំងដោយនិយាយពង្រីកនូវអ្វីដែលបានសង្កេតឃើញ (**កញ្ចក់ពង្រីក**) ។

**ក. កញ្ចក់កក់ក្ដៅ** (ផ្ដោតលើការយល់ចិត្ត និងអធ្យាស្រ័យ)

គ្រូណែនាំពិពណ៌នាអំពីអត្ថន័យនៃពាក្យសម្ដី កាយវិការ និងអត្តចរិតខាងក្រៅរបស់កម្មសិក្សាការី ការិនី ឱ្យបានច្បាស់លាស់តាមដែលអាចធ្វើបាន ។ នៅចំណុចនេះគ្រូណែនាំបង្ហាញការយល់ចិត្ត និងការអធ្យាស្រ័យទៅកាន់កម្មសិក្សាការី ការិនី ។

ឧទាហរណ៍:

- ***កម្មសិក្សាការី ការិនី៖*** *"ឥឡូវនេះកម្មសិក្សាការី ការិនីពីរនាក់នៅក្នុងក្រុមរបស់ខ្ញុំបានឈឺមួយសប្ដាហ៍ហើយ ដូច្នេះខ្ញុំត្រូវធ្វើការរៀបចំមេរៀនច្រើនជាងមុនតែម្នាក់ឯងដោយគ្មានដៃគូពិភាក្សា ។ ខ្ញុំមានអារម្មណ៍ថាខ្ញុំមានបន្ទុកការងារជាច្រើនដែលត្រូវធ្វើម្នាក់ឯង"*

- **គ្រូណែនាំ:** *"បើតាមខ្ញុំយល់ប្អូនហាក់ដូចជាមានអារម្មណ៍តានតឹង និងឯកោម្នាក់ឯង ហើយមិនច្បាស់ថាតើប្អូនត្រូវចាត់ចែងការងារទាំងនេះដោយរបៀបណា ។ តើខ្ញុំនិយាយត្រូវឬទេ?"*

**ខ. កញ្ចក់ត្រជាក់** (ផ្តោតលើភាពជាក់ស្តែង និងខ្លឹមសារ មិនផ្តោតលើអារម្មណ៍កម្មសិក្សាការី ការិនីទេ)

គ្រូណែនាំបរិយាយតែរឿងពិតជាក់ស្តែង និងអ្វីដែលគាត់បានសង្កេតឃើញ ។ គ្រូណែនាំផ្តោតការយកចិត្តទុកដាក់តែលើការដោះស្រាយបញ្ហា ជាជាងផ្តោតលើអារម្មណ៍របស់គរុសិស្ស ។

ឧទាហរណ៍៖ បញ្ហាតែមួយប៉ុន្តែការឆ្លើយតបរបស់គ្រូណែនាំខុសគ្នា

- *កម្មសិក្សាការី ការិនី៖ "ឥឡូវនេះកម្មសិក្សាការី ការិនីពីរនាក់នៅក្នុងក្រុមរបស់ខ្ញុំបានឈឺមួយសប្តាហ៍ហើយ ដូច្នេះខ្ញុំត្រូវធ្វើការរៀបចំមេរៀនច្រើនជាងមុនតែម្នាក់ឯងដោយគ្មានដៃគូពិភាក្សា ។ ខ្ញុំមានអារម្មណ៍ថាខ្ញុំមានបន្ទុកការងារជាច្រើនដែលត្រូវធ្វើតែម្នាក់ឯង"*

- **គ្រូណែនាំ:** *"អវត្តមានកម្មសិក្សាការី ការិនី២នាក់នៅក្នុងក្រុមរបស់ប្អូនបានបង្កជាបញ្ហាដល់ប្អូន ដែលចាំបាច់ត្រូវរកដំណោះស្រាយ ។ តើខ្ញុំនិយាយនេះត្រូវឬទេ?"*

**គ. កញ្ចក់ពង្រីក** (និយាយពង្រីកនូវអ្វីដែលអ្នកបានឃើញ និងឮ ហើយធ្វើការបកស្រាយ)

កញ្ចក់ពង្រីករៀបចំឡើងដើម្បីពង្រីកនូវអ្វីដែលអ្នកបានសង្កេតឃើញ ។ វាផ្តោតសំខាន់លើអ្វីៗ ដែលគ្រូណែនាំបានសង្កេតឃើញ ហើយគាត់បកស្រាយអ្វីដែលគាត់បានសង្កេតឃើញ ដោយព្យាយាមពង្រីកបញ្ហានោះឱ្យធំ ហើយសួរបញ្ជាក់ថាតើកម្មសិក្សាការី ការិនី នោះយល់ព្រមដែរឬទេ ។ តាមពិតគឺសួរបញ្ជាក់ពីកម្មសិក្សាការី ការិនី តើការបកស្រាយរបស់គាត់ត្រឹមត្រូវឬទេ?

ឧទាហរណ៍៖ បញ្ហាតែមួយប៉ុន្តែការឆ្លើយតបរបស់គ្រូណែនាំខុសគ្នា

- កម្មសិក្សាការី ការិនី៖ *"ឥឡូវនេះកម្មសិក្សាការី ការិនីពីរនាក់នៅក្នុងក្រុមរបស់ខ្ញុំបានឈឺមួយសប្តាហ៍ហើយ ដូច្នេះខ្ញុំត្រូវធ្វើការរៀបចំមេរៀនច្រើនជាងមុនតែម្នាក់ឯងដោយគ្មានដៃគូពិភាក្សា ។ ខ្ញុំមានអារម្មណ៍ថាខ្ញុំមានបន្ទុកការងារជាច្រើនដែលត្រូវធ្វើម្នាក់ឯង"*

- **គ្រូណែនាំ:** *"អ្វីដែលប្អូនបាននិយាយ ខ្ញុំយល់ថាកម្មសិក្សាការី ការិនីពីរនាក់នោះគន្លងមកបានជួយការងារប្អូនច្រើនហើយ ចាប់ពីពេលនេះតទៅប្អូនហាក់ដូចជាឯកោមិនដឹងត្រូវដោះស្រាយបញ្ហានេះដោយវិធីណា ។ តើខ្ញុំនិយាយនេះត្រឹមត្រូវឬទេ?"*

កញ្ចក់ឆ្លុះបញ្ចាំងទាំងបីខាងលើ អាចមានប្រសិទ្ធភាពទៅលើការឆ្លុះបញ្ចាំងតាមស្ថានភាពជាក់ស្តែង ។ នៅពេលដែលកម្មសិក្សាការី ការិនីមានឱកាសសម្តែងអារម្មណ៍ ពួកគេអាចគិតថាមានគេយល់ពីអារម្មណ៍របស់ខ្លួននិងមានការគាំទ្រ (កញ្ចក់កក់ក្តៅ) ។

ក្នុងករណីខ្លះកម្មសិក្សាការី ការិនីគ្រាន់តែចង់ដោះស្រាយបញ្ហារបស់ពួកគេ ដោយមិនចង់ពិភាក្សាពីអារម្មណ៍របស់ពួកគេឡើយ (កញ្ចក់ត្រជាក់) ។

ម្យ៉ាងទៀតការនិយាយពង្រីកបញ្ហាអ្វីមួយ វាអាចជួយឱ្យកម្មសិក្សាការី ការិនីឱ្យមើលឃើញបញ្ហានោះកាន់តែច្បាស់ (កញ្ចក់ពង្រីក) ។ វាក៏អាចជួយកម្មសិក្សាការី ការិនីឱ្យមើលឃើញថាអ្វីៗទាំងអស់មិនសុទ្ធតែអាក្រក់ដូចការគិតរបស់ខ្លួនឡើយ និងធ្វើឱ្យពួកគេចាប់ផ្តើមគិតរកដំណោះស្រាយងាយៗ តាមលទ្ធភាពដែលខ្លួនមាន ។

### ២.៤.៣ ការកែលម្អតាមបែបស្ថាបនា

គឺជាការប្រើប្រាស់នូវសារកែលម្អអំពីឥរិយាបថ អាកប្បកិរិយា និងសកម្មភាពបង្រៀន និងរៀនរបស់កម្មសិក្សាការី ការិនីប្រកបដោយភាពខ្វល់ខ្វាយ និងយកចិត្តទុកដាក់ ប៉ុន្តែមិនបង្កឱ្យប៉ះពាល់ដល់ទំនាក់ទំនងល្អរវាងគ្រូណែនាំ និងកម្មសិក្សាការី ការិនីទេ ។

ឧទាហរណ៍៖ "ខ្ញុំដឹងថាប្អូននឹងមានការលំបាកក្នុងការស្តាប់រឿងនេះ (ការរក្សាទំនាក់ទំនងល្អ) ប៉ុន្តែតាមគំនិតខ្ញុំយល់ថា ប្អូនត្រូវតែពង្រឹងចំណេះដឹងរបស់ខ្លួនលើមុខវិជ្ជាគណិតវិទ្យាបន្ថែមទៀត (ខ្លឹមសារ)" ។

#### ២.៤.៣.១ ការសរសើរ និងការកែលម្អ

គេនិយាយថា៖ "មនុស្សភាគច្រើនពិបាកទទួលយកការកែលម្អ" ។ ដើម្បីឱ្យគាត់អាចទទួលយកការកែលម្អបាន លុះត្រាតែមានការសរសើរឱ្យបានគ្រប់គ្រាន់ ។ ម្យ៉ាងទៀត បើមានគេសរសើរ យើងតែងតែចង់ដឹង និងចង់ឮនូវពាក្យសម្តីរបស់គេ ។

ដូចនេះដើម្បីឱ្យកម្មសិក្សាការី ការិនីយកអនុសាសន៍ទៅអនុវត្តបានល្អ គ្រូណែនាំត្រូវប្រើវិធីកែលម្អតាមបែបស្ថាបនា (ទាំងការសរសើរ ទាំងកែលម្អ) ក្នុងពេលផ្តល់ព័ត៌មានត្រឡប់ ។ ការកែលម្អតាមបែបស្ថាបនាមានន័យថា ទាំងសារខ្លឹមសារ និងសារទំនាក់ទំនងមានសារៈសំខាន់ដូចគ្នា ។ កម្មសិក្សាការី ការិនីនឹងមានចិត្តចង់ស្តាប់ពីចំណុចកែលម្អ នៅពេលដែលមានទំនាក់ទំនងល្អ និងមានការសរសើរពីគ្រូណែនាំ ។

**ការកែលម្អតាមបែបស្ថាបនា គួរចៀសវាងចំណុចដូចខាងក្រោម៖**

- **និយាយត្រង់ៗ ឬនិយាយចំៗពេក**
  ប្រសិនបើសារដែលផ្តល់ឱ្យមានលក្ខណៈត្រង់ពេក វាអាចធ្វើឱ្យប៉ះពាល់ដល់អារម្មណ៍របស់កម្មសិក្សាការី ការិនី ហើយកម្មសិក្សាការី ការិនីអាចរកវិធីនិយាយតបតវិញដើម្បីការពារខ្លួន ឬមិនព្រមទទួលយកគំនិតកែលម្អនោះទៅអនុវត្ត ។

- **ប្រុងប្រយ័ត្នពេក**
  ពេលខ្លះគ្រូណែនាំអាចផ្តល់ការកែលម្អតាមបែបស្ថាបនាដល់កម្មសិក្សាការី ការិនីដោយប្រុងប្រយ័ត្នពេក ដោយសារតែគាត់មិនចង់ឱ្យប៉ះពាល់ដល់អារម្មណ៍របស់កម្មសិក្សាការី ការិនី ។ គាត់បារម្ភថាទំនាក់ទំនងរបស់គាត់ជាមួយកម្មសិក្សាការី ការិនីអាចមិនសូវល្អ នៅពេលដែលគាត់ធ្វើការកែលម្អចំៗពេក ជាហេតុធ្វើឱ្យគាត់សម្រេចចិត្តថាមិននិយាយប្រាប់កម្មសិក្សាការី ការិនីនោះ ។ នៅពេលដែលគ្រូណែនាំ

គិតតែពីទំនាក់ទំនងខ្លាំងពេក ធ្វើឱ្យខ្លឹមសារដែលផ្ដល់ឱ្យកម្មសិក្សាការី ការិនីមិនច្បាស់លាស់ និងមិនជាក់លាក់។ នៅចុងបញ្ចប់កម្មសិក្សាការី ការិនីមិនដឹងពីចំណុចកែលម្អដែលខ្លួនត្រូវអនុវត្តបន្ត ។

ដូច្នេះដើម្បីឱ្យការផ្ដល់ព័ត៌មានត្រឡប់មានប្រសិទ្ធភាព យើងត្រូវធ្វើការកែលម្អតាមបែបស្ពានដោយប្រើប្រាស់ "**សារទំនាក់ទំនង - សារខ្លឹមសារ**" ។

### ២.៤.៣.២ សារទំនាក់ទំនង–សារខ្លឹមសារ

ពេលផ្ដល់ព័ត៌មានត្រឡប់ សារទំនាក់ទំនង និងសារខ្លឹមសារមានសារៈសំខាន់ដូចគ្នា ។ ការប្រើប្រាស់ "សារទំនាក់ទំនង–សារខ្លឹមសារ" បង្កភាពងាយស្រួលក្នុងការផ្ដល់ និងទទួលយកព័ត៌មានត្រឡប់ ។

**ក. <u>សារទំនាក់ទំនង</u>**

គឺជាការបញ្ចេញនូវអារម្មណ៍ និងឥរិយាបថរបស់មនុស្សពីរនាក់ ឬច្រើននាក់ ។ ក្នុងពេលផ្ដល់ព័ត៌មានត្រឡប់ ចាំបាច់ត្រូវមានទំនាក់ទំនងល្អ ដើម្បីឱ្យកម្មសិក្សាការី ការិនីមានភាពកក់ក្ដៅ ។ ពួកគេអាចរៀនសូត្របានច្រើន នៅពេលដែលពួកគេមានអារម្មណ៍កក់ក្ដៅ និងមិនភ័យខ្លាចក្នុងការធ្វើទំនាក់ទំនងជាមួយគ្រូណែនាំ ។ ទំនាក់ទំនងល្អអាចកើតមានឡើង នៅពេលដែលយើងប្រើប្រាស់ពាក្យពេចន៍បានសមរម្យ និងឥរិយាបថរួសរាយរាក់ទាក់ (ការស្ដាប់ដោយសកម្ម) ។

ឧទាហរណ៍៖

- ខ្ញុំមិនចង់ធ្វើឱ្យប្អូនមិនសប្បាយចិត្តនោះទេ...
- ខ្ញុំមិនចង់ឱ្យប្អូនបាត់បង់ទំនុកចិត្ត...
- ខ្ញុំឃើញថាប្អូនកំពុងតែព្យាយាម...
- ខ្ញុំយល់ថាប្អូនមានការពិបាក...
- ខ្ញុំចង់ជួយប្អូន...
- ខ្ញុំឃើញថាប្អូនមានអារម្មណ៍មិនសូវសប្បាយ...
- ខ្ញុំមិនចង់ធ្វើឱ្យប្អូនមានអារម្មណ៍ថា ប្អូនកំពុងធ្វើអ្វីខុសនោះទេ...
- ប្អូនមិនគួរមានអារម្មណ៍មិនល្អចំពោះការបង្រៀនរបស់ប្អូនឡើយ...
- ខ្ញុំគិតថាប្អូនមានការលំបាកក្នុងការស្ដាប់អ្វីដែលបានលើកឡើងនេះ...
- ខ្ញុំពេញចិត្តចំពោះការខិតខំប្រឹងប្រែងរបស់ប្អូន...
- ...

ខ. <u>សារខ្លឹមសារ</u>

ក្នុងពេលផ្តល់ព័ត៌មានត្រឡប់ចាំបាច់ត្រូវប្រាប់ពីចំណុចដែលត្រូវកែលម្អ ។ ចំណុចដែលត្រូវកែលម្អទាំងនេះអាចជាព័ត៌មាន និងជាខ្លឹមសារដែលមានប្រយោជន៍ដល់កម្មសិក្សាការី ការិនីដើម្បីយកទៅអនុវត្ត ។

ឧទាហរណ៍:

- ខ្ញុំគិតថាវិធីនេះប្រើមិនបានជោគជ័យទេ
- ខ្ញុំកត់សម្គាល់ឃើញថាប្អូនមានការលំបាកក្នុងការគ្រប់គ្រងថ្នាក់រៀន
- សំឡេងរបស់ប្អូនខ្សោយពេក
- ខ្ញុំគិតថាប្អូនប្រើប្រាស់សម្ភារឧបទេសមិនទាន់បានគ្រប់គ្រាន់
- ខ្ញុំគិតថាប្អូនមិនបានយកចិត្តទុកដាក់មើលថាសិស្សពាក់កណ្តាលថ្នាក់មិនបានយកចិត្តទុកដាក់ស្តាប់ប្អូន
- ខ្ញុំគិតថាប្អូនគួរត្រៀមរៀបចំកិច្ចតែងការបង្រៀនឱ្យបានល្អជាងនេះ
- ខ្ញុំគិតថាប្អូនមិនបានកែលម្អតាមអនុសាសន៍ខ្ញុំដែលបានផ្តល់ពីលើកមុនទេ
- ប្អូនត្រូវពិនិត្យអក្ខរាវិរុទ្ធឡើងវិញ
- ខ្ញុំគិតថាប្អូនត្រូវកែលម្អការសរសេរលើក្តារខៀនឡើងវិញ
- ខ្ញុំសង្កេតឃើញថាប្អូនមានការយឺតយ៉ាវក្នុងការមកបង្រៀន

**គ. ការផ្សារភ្ជាប់ "សារទំនាក់ទំនង–សារខ្លឹមសារ"**

- គ្រូណែនាំសង្កេតឃើញកម្មសិក្សាការី ការិនីម្នាក់មានការតាំងចិត្តល្អ ប៉ុន្តែសកម្មភាព ឬការប្រព្រឹត្តរបស់គាត់មិនទាន់បានល្អនៅឡើយ ។
  *ឧទាហរណ៍៖ "ខ្ញុំមើលឃើញថាអ្នកមានការតាំងចិត្តល្អ (សារទំនាក់ទំនង) ប៉ុន្តែខ្ញុំគិតថា ល្បែងសិក្សាដែលប្អូនយកមកលេងនេះមិនទាន់ស្របតាមកម្រិតថ្នាក់ទេ (សារខ្លឹមសារ)" ។*
- គ្រូណែនាំខ្លាចក្នុងការធ្វើឱ្យកម្មសិក្សាការីការិនីមិនសប្បាយចិត្ត។
  *ឧទាហរណ៍៖ "ខ្ញុំមិនចង់ធ្វើឱ្យប្អូនមិនសប្បាយចិត្តនោះទេ ផ្ទុយទៅវិញខ្ញុំពិតជាបារម្ភពីប្អូន (សារទំនាក់ទំនង) ប៉ុន្តែខ្ញុំសង្កេតឃើញថាសំឡេងរបស់ប្អូនខ្សោយពេក ដែលធ្វើឱ្យសិស្សស្តាប់មិនឮ (សារខ្លឹមសារ)" ។*
- គ្រូណែនាំអាចធ្វើការសន្និដ្ឋានបានថាវាពិតជាមានការលំបាកមែន។
  *ឧទាហរណ៍៖ "ខ្ញុំមានការពិបាកក្នុងការនិយាយចេញមក ព្រោះខ្ញុំក៏ធ្លាប់មានកំហុសដែរ ដូចនេះខ្ញុំយល់ពីមូលហេតុដែលអ្នកបានធ្វើ ។ ទោះជាយ៉ាងណាខ្ញុំគិតថាអ្នកមិនគួរស្រែកសំឡុតដាក់សិស្សទេ" ។*
- គ្រូណែនាំអាចដឹងថាកម្មសិក្សាការី ការិនីពិបាកយល់ពីចិត្តគំនិតរបស់គាត់ ។
  *ឧទាហរណ៍៖ "ខ្ញុំគិតថាអ្នកប្រហែលជាពិបាកក្នុងការស្តាប់បញ្ហានេះ (សារទំនាក់ទំនង) ។ ទោះជាយ៉ាងណា ខ្ញុំយល់ថាអ្នកមិនគួរជេរស្តីសិស្សនោះទេ (សារខ្លឹមសារ)" ។*

### ចំណុចដែលត្រូវយកចិត្តទុកដាក់

ក្នុងការផ្តល់ព័ត៌មានត្រឡប់ គ្រូណែនាំត្រូវ៖

- **ធ្វើឱ្យបានញឹកញាប់ និងភ្លាមៗ**
  នៅពេលដែលគ្រូណែនាំ និងកម្មសិក្សាការី ការិនីពិភាក្សាគ្នាឱ្យបានញឹកញាប់ពីចំណុចត្រូវកែលម្អតាម បែបស្ថាបនា វានឹងក្លាយជាទម្លាប់ល្អមួយ ។ ប្រសិនបើគ្រូណែនាំរង់ចាំដល់យូរៗ ទើបផ្តល់ព័ត៌មានត្រឡប់ម្តង ហើយលើកឡើងពីមតិកែលម្អច្រើនលើសលប់ពេក វាធ្វើឱ្យកម្មសិក្សាការី ការិនី មានការភ្ញាក់ផ្អើល និងមិនសប្បាយចិត្ត ។ គ្រូណែនាំមិនត្រូវរង់ចាំយូរពេកនោះទេ ពីព្រោះគាត់អាចនឹងភ្លេចពីចំណុចដែលត្រូវផ្តល់ឱ្យកម្មសិក្សាការី ការិនីដើម្បីធ្វើការកែលម្អ ហើយកម្មសិក្សាការី ការិនីក៏អាចភ្លេចសកម្មភាពបង្រៀនរបស់ខ្លួនដែរ ។

- **ធ្វើបន្តិចម្តងៗ**
  គ្រូណែនាំមិនត្រូវលើកឡើងពីចំណុចដែលត្រូវកែលម្អច្រើនពេកទេ ព្រោះវាធ្វើឱ្យកម្មសិក្សាការី ការិនីមានអារម្មណ៍ថាច្រើនហួសពេក ដែលមិនអាចយកទៅអនុវត្តបានគ្រប់ចំណុច ។ ពេលផ្តល់ព័ត៌មានត្រឡប់គ្រូណែនាំគួរផ្តល់អនុសាសន៍មិនឱ្យលើសពី បីចំណុចដែលចាំបាច់បំផុតនោះទេ ។

- **ប្រើសារឱ្យបានច្បាស់លាស់**
  សារទំនាក់ទំនង និងសារខ្លឹមសារត្រូវតែមានភាពច្បាស់លាស់ដើម្បីកែលម្អ និងជួយគាំទ្រដល់កម្មសិក្សាការី ការិនី។

### ២.៤.៤. ការប្រើប្រាស់ "សារផ្តើមដោយពាក្យ ខ្ញុំ"

គ្រូណែនាំគួរប្រើប្រាស់ "សារផ្តើមដោយពាក្យខ្ញុំ" ដើម្បីរក្សាបរិយាកាសបែបសហការ ។ "សារផ្តើមដោយពាក្យ**ខ្ញុំ**" មានប្រសិទ្ធភាពជាង "សារផ្តើមដោយពាក្យ**អ្នក**" ជាពិសេសនៅពេលដែលអ្នកលើកឡើងពីឥរិយាបថរបស់នរណាម្នាក់ ។

ឧទាហរណ៍: ប្រសិនបើគ្រូណែនាំនិយាយថា: "**អ្នក**មិនបានប្រើប្រាស់សម្ភារឧបទេស ឱ្យបានគ្រប់គ្រាន់នោះទេ" កម្មសិក្សាការី ការិនីនឹងមានអារម្មណ៍ថាខ្លួនទទួលបានការស្តីបន្ទោស ហើយមានអារម្មណ៍ភ័យព្រួយ ។

គ្រូណែនាំនិយាយថា: "**ខ្ញុំ**នឹងមានការពេញចិត្តជាងនេះ ប្រសិនបើអ្នកប្រើសម្ភារឧបទេសឱ្យបានច្រើនជាងមុន" ។ កម្មសិក្សាការី ការិនីនឹងមានអារម្មណ៍ថាមានការលើកទឹកចិត្តក្នុងការអនុវត្តសកម្មភាពផ្សេងៗបន្តទៀត ។

ការប្រើប្រាស់ "**សារផ្តើមដោយប្រើពាក្យខ្ញុំ...**" គ្រូណែនាំហាក់ដូចជាចូលរួមចំណែកទទួលខុសត្រូវ យកបញ្ហារបស់កម្មសិក្សាការី ការិនីដើម្បីរកដំណោះស្រាយរួមគ្នា ។ ប្រសិនបើគ្រូណែនាំប្រើសារផ្តើមដោយពាក្យខ្ញុំ... នោះធ្វើឱ្យកម្មសិក្សាការី ការិនីមិនបដិសេធលើការផ្តល់ព័ត៌មានត្រឡប់របស់គាត់ ពីព្រោះវាឆ្លុះបញ្ចាំងលើអារម្មណ៍ និងគំនិតរបស់អ្នកនិយាយ ។

ការប្រើសារផ្ដើមដោយពាក្យ**ខ្ញុំ** គឺមិនវាយប្រហារខ្លាំងទៅកាន់កម្មសិក្សាការី ការិនី ផ្ទុយទៅវិញវាជាការបង្ហាញទំនាក់ទំនងល្អក្នុងការដោះស្រាយបញ្ហារួមគ្នា ។

## អត្ថន័យខុសគ្នានៃ "សារផ្ដើមដោយពាក្យអ្នក..." និង "សារផ្ដើមដោយពាក្យខ្ញុំ..."

| សារផ្ដើមដោយពាក្យអ្នក... | សារផ្ដើមដោយពាក្យខ្ញុំ... |
|---|---|
| • ដាក់កំហុសឱ្យកម្មសិក្សាការី ការិនី<br>• ធ្វើឱ្យកម្មសិក្សាការី ការិនីបដិសេធ ឬនិយាយការពារខ្លួន និងមានអារម្មណ៍ខ្វះទំនុកចិត្ត<br>• ធ្វើឱ្យកម្មសិក្សាការី ការិនីមិនយកចិត្តទុកដាក់បំពេញការងារ ។ | • ធ្វើឱ្យកម្មសិក្សាការី ការិនី យល់ពីបញ្ហាតាមរយៈអ្វីដែលអ្នកនិយាយ<br>• ធ្វើឱ្យកម្មសិក្សាការី ការិនីមិនមានអារម្មណ៍ត្រូវបានវាយប្រហារ<br>• ធ្វើឱ្យកម្មសិក្សាការី ការិនីបើកចិត្តទូលាយក្នុងការស្ដាប់និងកែលម្អ ។ |
| ឧ. **អ្នក**តែងតែមកសាលារៀនយឺតជាញឹកញាប់ ។ | ឧ. **ខ្ញុំ**ពេញចិត្ត នៅពេលប្អូនមកដល់សាលារៀនទាន់ពេលវេលា ។ |

**ឧទាហរណ៍: ការប្ដូរពីសារផ្ដើមដោយពាក្យអ្នក... មកសារផ្ដើមដោយពាក្យខ្ញុំ..**

សារផ្ដើមដោយពាក្យអ្នក: **អ្នក**មិនបានប្រគល់កិច្ចតែងការបង្រៀនឱ្យខ្ញុំទាន់ពេលវេលា ។
សារផ្ដើមដោយពាក្យខ្ញុំ : **ខ្ញុំ**មិនអាចត្រៀមរៀបចំការសង្កេតការបង្រៀនបានល្អទេ ប្រសិនបើខ្ញុំមិនបានទទួលកិច្ចតែងការបង្រៀនទាន់ពេលវេលា ។

សារផ្ដើមដោយពាក្យអ្នក : **អ្នក**ប្រើសម្ភារឧបទេសតូចៗពេកក្នុងពេលបង្រៀន ។
សារផ្ដើមដោយពាក្យខ្ញុំ : **ខ្ញុំ**គិតថាសិស្សមានភាពងាយស្រួលក្នុងការមើល ប្រសិនបើសម្ភារឧបទេសទាំងនោះធំៗជាងនេះ ។

សារផ្ដើមដោយពាក្យអ្នក : **អ្នក**មិនបានឆ្លើយនូវសំណួររបស់ខ្ញុំទេ ។
សារផ្ដើមដោយពាក្យខ្ញុំ : **ខ្ញុំ**មានការពិបាក នៅពេលដែលខ្ញុំមិនបានទទួលចម្លើយរបស់អ្នក។

# ផ្នែកទី៣

# ជំហាននៃការផ្តល់ព័ត៌មានត្រឡប់



# ផ្នែកទី ៣: ជំហាននៃការផ្តល់ព័ត៌មានត្រឡប់

**គោលបំណង:** បង្ហាញពីជំហានសំខាន់ៗក្នុងការផ្តល់ព័ត៌មានត្រឡប់ ឱ្យទទួលបានជោគជ័យ

### ៣.១ ទិដ្ឋភាពទូទៅ

ដំណើរការផ្តល់ព័ត៌មានត្រឡប់គឺជាការសន្ទនារវាងគ្រូណែនាំ និងកម្មសិក្សាការី ការិនី ជាទូទៅធ្វើឡើងបន្ទាប់ពីសង្កេតការបង្រៀន ។ ក្នុងពេលផ្តល់ព័ត៌មានត្រឡប់ គ្រូណែនាំត្រូវដឹកនាំការពិភាក្សាតាមជំហានទាំងប្រាំមួយ ដែលយើងអាចហៅថាជំហានក្នុងការផ្តល់ព័ត៌មានត្រឡប់ ។

ការផ្តល់ព័ត៌មានត្រឡប់គួរតែមានរយៈពេលយ៉ាងតិចពី១០នាទី ទៅ២០នាទី ហើយផ្តល់ឱកាសឱ្យកម្មសិក្សាការី ការិនីចូលរួមបញ្ចេញមតិយោបល់របស់ខ្លួនឱ្យបានច្រើន ។ ពេលខ្លះរយៈពេលនេះក៏មានភាពបត់បែនដែរ វាអាស្រ័យលើបញ្ហាច្រើន ឬតិចដែលត្រូវលើកឡើងដោយគ្រូណែនាំ ឬដោយកម្មសិក្សាការី ការិនី។

### ការផ្តល់ព័ត៌មានត្រឡប់មាន ប្រាំមួយជំហាន

1. សេចក្តីផ្តើម
2. ចំណាប់អារម្មណ៍របស់កម្មសិក្សាការី ការិនីលើលទ្ធផលនៃការបង្រៀន និងរៀន
3. ការផ្តល់ព័ត៌មានត្រឡប់របស់គ្រូណែនាំ
4. ការចោទសួរឱ្យកម្មសិក្សាការី ការិនីបញ្ចេញយោបល់លើអ្វីដែលបានលើកឡើង
5. ការពិភាក្សាគ្នារកមធ្យោបាយកែលម្អលទ្ធផលសម្រាប់អនុវត្តលើកក្រោយ
6. ការបូកសរុប ដោយសួរសំណួរ និងកំណត់ពេលជួបលើកក្រោយ។

**DVDបំណិនព័ត៌មានត្រឡប់**

- វីដេអូទី៣៖

  បង្ហាញពីដំណើរការផ្តល់ព័ត៌មានត្រឡប់ជំហានទាំងប្រាំមួយ

### ៣.២ ជំហាននៃការផ្តល់ព័ត៌មានត្រឡប់

ការផ្តល់ព័ត៌មានត្រឡប់ត្រូវអនុវត្តតាមជំហានទាំង៦ដូចខាងក្រោម៖

#### ជំហានទី១: សេចក្តីផ្តើម

ជាទូទៅការផ្តល់ព័ត៌មានត្រឡប់ឱ្យទទួលបានលទ្ធផលល្អ គួរតែមានការចូលរួមនិងលើកទឹកចិត្តដល់ដៃគូពិភាក្សាដែលត្រូវអនុវត្តតាមចំណុចសំខាន់ៗដូចខាងក្រោម៖

- សំណេះសំណាលជាមួយកម្មសិក្សាការី ការិនីដើម្បីបញ្ចៀសអារម្មណ៍តានតឹង និងភាពភ័យខ្លាច
- បង្ហាញគោលបំណងឱ្យបានច្បាស់លាស់

➢ **សំណេះសំណាលជាមួយគរុសិស្ស**

ការចាប់ផ្តើមដំបូងនៃការផ្តល់ព័ត៌មានត្រឡប់ គ្រូណែនាំត្រូវចៀសវាងនិយាយតែម្នាក់ឯង ព្រោះវាធ្វើឱ្យប៉ះពាល់ដល់ដំណើរការពិភាក្សា និងនាំឱ្យគ្រូណែនាំប្រើទម្លាប់ចាស់ ដែលភាគច្រើនកម្មសិក្សាការី ការិនី ពឹងផ្អែកតែលើអនុសាសន៍របស់គ្រូណែនាំ ។

គ្រូណែនាំអាចចាប់ផ្តើមដោយនិយាយសំណេះសំណាលជាមួយកម្មសិក្សាការី ការិនី ឬការលើកសរសើរ ដើម្បីបង្កើតភាពស្និទ្ធស្នាល និងមានអារម្មណ៍មិនភ័យខ្លាច ។

➢ **បង្ហាញគោលបំណង ឱ្យបានច្បាស់លាស់**

គ្រូណែនាំបង្ហាញពីគោលបំណង នៃការជួបគ្នាក្នុងពេលផ្តល់ព័ត៌មានត្រឡប់ ។

*ឧទាហរណ៍៖*

"នេះជាលើកទី២ ហើយដែលយើងបានជួបគ្នា ។ គោលបំណងនៃការជួបប្អូនថ្ងៃនេះ ដើម្បីពិនិត្យការរីកចម្រើន នៃការបង្រៀន និងរៀនរបស់ប្អូន ។ វាជាការល្អណាស់ ប្រសិនបើប្អូនអាចធ្វើការឆ្លុះបញ្ចាំងដោយខ្លួនឯងទន្ទឹមនឹងនេះ ប្អូនក៏អាចសួរសំណួរបានដែរ ។ តើប្អូនយល់យ៉ាងដូចម្តេចដែរ?"

#### ជំហានទី២: ចំណាប់អារម្មណ៍របស់កម្មសិក្សាការី ការិនី លើលទ្ធផលនៃការបង្រៀន

គ្រូណែនាំឱ្យកម្មសិក្សាការី ការិនីឆ្លុះបញ្ចាំងលើការបង្រៀននិងរៀនរបស់ពួកគេជាមុន ។ តើប្អូនពេញចិត្តនឹងដំណើរការបង្រៀនរបស់ប្អូនដែរឬទេ? បើពេញចិត្តហេតុអ្វី? បើមិនពេញចិត្តតើមូលហេតុអ្វី?

ប្រសិនបើកម្មសិក្សាការី ការិនីមិនអាចឆ្លុះបញ្ចាំងលើការបង្រៀន និងរៀនរបស់ខ្លួនបានគ្រូណែនាំគប្បីប្រើសំណួរជំនួយដូចខាងក្រោម៖

- តើមេរៀនរបស់ប្អូនមានវត្ថុបំណងឱ្យសិស្សចេះពីអ្វីខ្លះ?
- តើប្អូនអនុវត្តបានតាមអ្វីដែលបានរំពឹងទុកឬទេ?
- តើមានចំណុចអ្វីខ្លះដែលទទួលបានជោគជ័យ?
- តើប្អូនបានធ្វើសកម្មភាពអ្វីខ្លះ? តើសិស្សបានធ្វើអ្វីខ្លះ?

- ចូររៀបរាប់ចំណុចល្អចំនួនពីរដែលប្អូនបានធ្វើ ។ តើហេតុអ្វីបានជាប្អូនគិតថាវាជាចំណុចល្អ?
- ចូររៀបរាប់ចំណុចមិនល្អចំនួនពីរដែលប្អូនបានធ្វើ ។ តើហេតុអ្វីបានជាប្អូនគិតថាវាជាចំណុចមិនល្អ?
- ពេលបង្រៀនមេរៀនក្រោយ តើប្អូននឹងកែលម្អអ្វីខ្លះ? ហេតុអ្វី?

គ្រូណែនាំមិនត្រូវសួរសំណួរទាំងអស់នេះក្នុងពេលតែមួយទេ ប៉ុន្តែត្រូវចេះជ្រើសរើសសំណួរណាដែលមានប្រយោជន៍ជាងគេ ក្នុងជំហាននេះដើម្បីជួយឱ្យកម្មសិក្សាការី ការិនីចេះគិត និងចេះរៀបរាប់ពីដំណើរការបង្រៀនរបស់ខ្លួន ។

## សារៈសំខាន់នៃស្វ័យឆ្លុះបញ្ចាំង

ស្វ័យឆ្លុះបញ្ចាំងមានសារៈសំខាន់ណាស់ ពីព្រោះវាជួយឱ្យយើងចេះគិត និងវិភាគលើសកម្មភាពរបស់ខ្លួនឯង ដើម្បីទទួលបានចំណេះដឹងបន្ថែមពីដំណើរការបង្រៀន និងរៀនរបស់យើង ។ តាមរយៈការធ្វើស្វ័យឆ្លុះបញ្ចាំងនេះ យើងអាចចេះកំណត់វិធីរៀនដោយខ្លួនឯង ទោះបីមិនមានអ្នកដទៃមកប្រាប់យើងក៏ដោយ ។

កម្មសិក្សាការី ការិនី គួរសួរខ្លួនឯងឱ្យបានញឹកញាប់នូវសំណួរដូចខាងក្រោម៖
- តើខ្ញុំមានឥរិយាបថដូចម្ដេច? (ទាំងភាសានិយាយ និងភាសាកាយវិការ)
- តើចំណុចអ្វីខ្លះដែលខ្ញុំធ្វើបានល្អ?
- តើចំណុចអ្វីខ្លះដែលខ្ញុំធ្វើមិនបានល្អ?
- តើខ្ញុំមានអារម្មណ៍ដូចម្ដេចចំពោះចំណុច ឬបញ្ហានេះ?
- តើអ្នកដទៃមានប្រតិកម្មអ្វីខ្លះមកលើឥរិយាបថរបស់ខ្ញុំ?

## ប្រសិនបើកម្មសិក្សាការី ការិនីមានការលំបាកក្នុងការធ្វើស្វ័យឆ្លុះបញ្ចាំង គ្រូណែនាំត្រូវ៖

**ក. អត់ធ្មត់៖**

គ្រូណែនាំត្រូវមានការអត់ធ្មត់ជាមួយកម្មសិក្សាការី ការិនី ពីព្រោះពួកគេមិនធ្លាប់មានបទពិសោធន៍ឆ្លើយសំណួរទាំងនេះទេ ។ គ្រូណែនាំត្រូវយល់ថាស្វ័យឆ្លុះបញ្ចាំង គឺជាបំណិនមួយដែលត្រូវការរៀនសូត្រ ហើយមិនមែនគ្រប់គ្នាសុទ្ធតែអាចចាប់បានភ្លាមៗទេ ។ ដើម្បីឱ្យចេះឆ្លុះបញ្ចាំងបានល្អទាមទារពេលវេលាច្រើនក្នុងការរៀនសូត្រ ។ គ្រូណែនាំត្រូវបង្រៀនកម្មសិក្សា ការី ការិនីឱ្យចេះធ្វើការឆ្លុះបញ្ចាំងតាមរយៈការសួរជាសំណួរ ។ បន្ទាប់មកកម្មសិក្សាការី ការិនីនឹងចេះសួរសំណួរទាំងនេះដោយខ្លួនឯង ។

### ខ. ពន្យល់៖

គ្រូណែនាំត្រូវពន្យល់ពីសារៈសំខាន់នៃស្វ័យឆ្លុះបញ្ចាំង ដើម្បីឱ្យកម្មសិក្សាការី ការិនីបានដឹងថា ធ្វើជាគ្រូបង្រៀន យើងចាំបាច់ត្រូវធ្វើស្វ័យឆ្លុះបញ្ចាំងឱ្យបានញឹកញាប់ ។ សូម្បីតែគ្រូបង្រៀន ដែលមានបទពិសោធន៍ច្រើន ក៏ត្រូវតែឆ្លុះបញ្ចាំងលើការបង្រៀនរបស់ខ្លួនឡើងវិញ ដើម្បីពិនិត្យ មើលថាតើសិស្សពិតជាយល់ការបង្រៀនរបស់គាត់ដែរឬទេ ។ ស្វ័យឆ្លុះបញ្ចាំងគឺជាបំណិន ដែលត្រូវការរៀនសូត្រ ហើយដំណើរការរៀនសូត្រនេះចាប់ផ្ដើមពេលកំពុងអនុវត្តកម្មសិក្សា គរុកោសល្យ ។ ពេលប្អូនបញ្ចប់ការសិក្សាប្អូនត្រូវចេះឆ្លុះបញ្ចាំងដោយខ្លួនឯង ។

### គ. ផ្លាស់ប្ដូរសំណួរ :

គ្រូណែនាំត្រូវផ្លាស់ប្ដូរសំណួរពីលំបាក ទៅសំណួរងាយស្រួល (ដូចដែលបានលើកឡើងខាងលើ) ដើម្បីជួយកម្មសិក្សាការី ការិនីឱ្យចេះធ្វើស្វ័យឆ្លុះបញ្ចាំង ។

ឧទាហរណ៍៖

- ខ្ញុំសង្កេតឃើញថាប្អូនបានធ្វើ...(លើកឡើងសកម្មភាពជាក់លាក់)...បានល្អណាស់។ តើប្អូនបានរៀបចំយ៉ាងដូចម្ដេច?
- តើប្អូនគិតថាការបង្រៀនរបស់ប្អូនបានសម្រេចវត្ថុបំណងឬទេនៅថ្ងៃនេះ? ហេតុអ្វី? តើប្អូន ដឹងដោយរបៀបណា?
- តើប្អូនគិតថាសិស្សបានរៀនទាំងអស់គ្នាឬទេ? តើប្អូនបានរៀបចំដោយវិធីណា?
- ខ្ញុំកត់សម្គាល់ឃើញថា ពេលខ្លះប្អូន...(លើកឡើងពីឥរិយាបថ ឬសកម្មភាពផ្សេងៗ) តើប្អូន អាចពន្យល់បានឬទេថាតើមូលហេតុអ្វីបានជាប្អូនអនុវត្តបែបនេះ?

## ជំហានទី ៣: ការផ្ដល់ព័ត៌មានត្រឡប់របស់គ្រូណែនាំ

ក្នុងការផ្ដល់ព័ត៌មានត្រឡប់ទៅកាន់កម្មសិក្សាការី ការិនី គ្រូណែនាំគប្បីយកចិត្តទុកដាក់លើពីរចំណុច៖

### ៣.១. ការសង្កេត

- ទាក់ទងនឹងឥរិយាបថកម្មសិក្សាការី ការិនី (ខ្ញុំឃើញអ្នក...)
- ទាក់ទងនឹងខ្លឹមសារមេរៀន វិធីសាស្ត្របង្រៀន និងសម្ភារឧបទេសរបស់កម្មសិក្សាការី ការិនី ។

### ៣.២. ការបកស្រាយពីអ្វីដែលបានសង្កេត

គ្រូណែនាំត្រូវបកស្រាយលើលទ្ធផលនៃការសង្កេតរបស់ខ្លួន

- " ខ្ញុំមានអារម្មណ៍ថា..."
- " តាមយោបល់ខ្ញុំ..."

ទោះបីក្នុងដំណាក់កាលនេះ យើងផ្តោតលើការងារវិជ្ជាជីវៈ ឬបំណិនបច្ចេកទេសក៏ដោយ តែការគាំទ្រផ្នែកចិត្តសាស្ត្រក៏មានសារៈសំខាន់ដែរ ។ គ្រូណែនាំត្រូវប្រុងប្រយ័ត្នលើការបកស្រាយរបស់ខ្លួនឱ្យបានច្បាស់លាស់ជាជាងធ្វើការបកស្រាយខុស ។

## គំរូនំហាំប៊ឺរហ្គ័រ

គំរូនំហាំប៊ឺរហ្គ័រ គឺជាវិធីល្អមួយក្នុងការផ្តល់មតិកែលម្អ ។ ការផ្តល់មតិកែលម្អលើចំណុចអវិជ្ជមានច្រើនអាចធ្វើឱ្យកម្មសិក្សាការី ការិនីមិនហ៊ានបង្ហាញពីគំនិតផ្តួចផ្តើមរបស់ខ្លួនហើយមានឥរិយាបថពឹងផ្អែកលើអ្នកដទៃ ។ កម្មសិក្សាការី ការិនីអាចរៀនសូត្របានល្អ នៅពេលគ្រូណែនាំបញ្ជាក់ពីសកម្មភាពរបស់ខ្លួនថាមានប្រសិទ្ធភាព និងភាពជោគជ័យ ។ ជាលទ្ធផលកម្មសិក្សាការី ការិនីបង្កើនស្វ័យភាព និងមិនសូវពឹងផ្អែកលើអ្នកដទៃ ។

ឧទាហរណ៍៖ ការផ្តល់មតិកែលម្អតាមគំរូនំហាំប៊ឺរហ្គ័រ

**ដំបូង:** គ្រូណែនាំត្រូវលើកសរសើរពីចំណុចវិជ្ជមានឱ្យបានច្រើន ដើម្បីលើកទឹកចិត្តកម្មសិក្សាការី ការិនី ។ ពួកគេចង់ស្តាប់មតិកែលម្អរបស់គ្រូណែនាំបន្ទាប់ពីបានឮពីចំណុចវិជ្ជមានជាមុន ។

**បន្ទាប់:** គ្រូណែនាំត្រូវលើកឡើងពីចំណុចគួរកែលម្អ តែមិនត្រូវលើកច្រើនចំណុចពេកទេ គួរលើកយកតែពីរ ឬបីចំណុចណាដែលសំខាន់ និងអាចឱ្យកម្មសិក្សាការី ការិនីយកទៅអនុវត្តបាន ។

**ចុងក្រោយ:** គ្រូណែនាំត្រូវបញ្ចប់ដោយលើកចំណុចវិជ្ជមានមួយ ឬពីរបន្ថែមទៀត ដើម្បីបញ្ជាក់ថាអ្វីដែលកម្មសិក្សាការី ការិនី កំពុងធ្វើពិតជាត្រឹមត្រូវ ។

## រូបភាពគំរូនំហាំប៊ឺរហ្គ័រ



## ជំហានទី៤: ការចោទសួរឱ្យកម្មសិក្សាការី ការិនីបញ្ចេញយោបល់លើអ្វីដែលបានលើកឡើង

គ្រូណែនាំផ្តល់ឱកាសឱ្យកម្មសិក្សាការី ការិនីឆ្លើយតបទៅនឹងការបកស្រាយរបស់គាត់ ។ កម្មសិក្សាការី ការិនីអាចយល់ស្រប ឬមិនយល់ស្របទៅលើអ្វីដែលគ្រូណែនាំបានលើកឡើង ។ ប្រសិនពួកគេមិនយល់ស្រប ទៅនឹងការលើកឡើងរបស់គ្រូណែនាំ ហើយបង្ហាញពីមូលហេតុបានច្បាស់លាស់ គ្រូណែនាំអាចធ្វើការផ្លាស់ប្តូរ យោបល់ដែលគាត់បានលើកឡើង និងត្រៀមគំនិតបន្តពិភាក្សារកដំណោះស្រាយនៅជំហានទី៥ ។

### សំណួរ

- " តើប្អូនយល់យ៉ាងណាដែរចំពោះមតិយោបល់ទាំងអស់ដែលខ្ញុំបានលើកឡើង? "
- " តើប្អូនយល់ពីអ្វីដែលខ្ញុំបាននិយាយដែរឬទេ? "

គ្រូណែនាំត្រូវយកចិត្តទុកដាក់ស្តាប់ដោយសកម្មទៅលើការឆ្លើយតបរបស់កម្មសិក្សាការី ការិនី ។ ប្រសិនបើគ្មាន ការឆ្លើយតបពីកម្មសិក្សាការី ការិនីទេ គ្រូណែនាំអាចប្រើវិធីមួយចំនួន ដែលបានលើកឡើងនៅជំហានទី២ (អត់ធ្មត់ ពន្យល់ និងផ្លាស់ប្តូរសំណួរ) ។

## ជំហានទី៥: ការពិភាក្សាផ្ទារកមធ្យោបាយកែលម្អសម្រាប់អនុវត្តលើកក្រោយ

គ្រូណែនាំសង្ខេបពីចំណុចត្រូវកែលម្អដែលបានលើកឡើងពីរ ឬបីចំណុចក្នុងជំហានទី៣ ដើម្បីពិភាក្សា និងរកដំណោះស្រាយ ។

ចំណុចដែលត្រូវកែលម្អខ្លះកម្មសិក្សាការីការិនីអាចរកវិធីដោះស្រាយដោយខ្លួនឯងបានបន្ទាប់ពីមានសំណួរបំផុស ពីគ្រូណែនាំដូចជា៖

- តើអ្នកអាចចាត់ចែងចំណុចកែលម្អនេះយ៉ាងដូចម្តេចនៅពេលក្រោយ?

ចំណុចដែលត្រូវកែលម្អខ្លះទៀត កម្មសិក្សាការី ការិនីត្រូវការមតិយោបល់ និងអនុសាសន៍មួយចំនួនពីគ្រូណែនាំ ដើម្បីជាដំណោះស្រាយ និងយកទៅអនុវត្ត ។

- តើវាជាការប្រសើរទេ ប្រសិនបើលើកក្រោយអ្នកព្យាយាម...
- ប្រហែលជាអ្នកអាចសាកល្បង...

### ជំហានទី ៦: ការបូកសរុបដោយសួរសំណួរ និងកំណត់ពេលជួបលើកក្រោយ

គ្រូណែនាំបូកសរុបការផ្ដល់ព័ត៌មានត្រឡប់ដោយសួរសំណួរ និងធ្វើការណាត់ជួបលើកក្រោយ

- **បូកសរុប និងសួរសំណួរ**
  - ឱ្យកម្មសិក្សាការី ការិនីសង្ខេបពីចំណុចដែលត្រូវយកទៅអនុវត្តដើម្បីធ្វើការកែលម្អ ។ ប្រសិនបើកម្មសិក្សាការី ការិនីមិនអាចរៀបរាប់បានអស់ទេ គ្រូណែនាំត្រូវសង្ខេបនូវចំណុចសំខាន់ៗមួយចំនួនរបស់ខ្លួនឡើងវិញ ។
  - ផ្ដល់ឱកាសឱ្យកម្មសិក្សាការី ការិនីសួរ ប្រសិនបើគេមានសំណួរបន្ថែមទៀត ។
  - សួរកម្មសិក្សាការី ការិនីថាតើគេពេញចិត្តនឹងការផ្ដល់ព័ត៌មានត្រឡប់នេះឬទេ ។

- **ណាត់ជួបលើកក្រោយ**
  - ធ្វើការណាត់ជួបលើកក្រោយ ។

### តារាងសង្ខេបជំហានទាំង ៦ ក្នុងការផ្ដល់ព័ត៌មានត្រឡប់

| ជំហាន | ខ្លឹមសារ | ប្រយោគដែលគ្រូណែនាំប្រើ | ឧទាហរណ៍ |
|---|---|---|---|
| ជំហានទី១៖ សេចក្ដីផ្ដើម | • សំណេះសំណាលដើម្បីកុំឱ្យកម្មសិក្សាការី ការិនីមានអារម្មណ៍ភ័យខ្លាច<br>• បង្ហាញគោលបំណងនៃការផ្ដល់ព័ត៌មានត្រឡប់នេះ។ | • គោលបំណងនៃការប្រជុំផ្ដល់ព័ត៌មានត្រឡប់នេះគឺ.......<br>• តើប្អូនយល់ស្របដែរឬទេ? | គោលបំណងនៃការផ្ដល់ព័ត៌មានត្រឡប់នេះគឺដើម្បីពិភាក្សាកែលម្អវិធីសាស្ត្របង្រៀន និងរៀនរបស់ប្អូន |

| | | | |
|---|---|---|---|
| ជំហានទី២៖ ចំណាប់អារម្មណ៍របស់កម្មសិក្សាការី ការិនីលើលទ្ធផល នៃការបង្រៀន និងរៀន | កម្មសិក្សាការី ការិនីបង្ហាញអំពីលទ្ធផលនៃការបង្រៀន និងរៀន (ចំណុចល្អ និងចំណុចដែលត្រូវកែលម្អ) | • តើប្អូនយល់យ៉ាងណាចំពោះ...?<br>• តើប្អូនគិតយ៉ាងណាទៅលើ...?<br>• តើមានចំណុចអ្វីខ្លះដែលទទួលបានជោគជ័យ? | • ចំណុចល្អមាន...<br>• ចំណុចដែលត្រូវកែលម្អមាន... |
| ជំហានទី៣៖ ការផ្ដល់ព័ត៌មានត្រឡប់របស់គ្រូណែនាំ | ៣.១.និយាយអំពីអ្វីដែលគ្រូណែនាំបានសង្កេតឃើញ ឬស្ដាប់ឮ<br>• ឥរិយាបថរបស់កម្មសិក្សាការី ការិនី<br>• ខ្លឹមសារ វិធីសាស្ត្រ សម្ភារឧបទេស និងលទ្ធផល | • ខ្ញុំកត់សម្គាល់ឃើញថាប្អូន...<br>• វិធីបង្រៀនរបស់ប្អូន...<br>• លទ្ធផលនេះទទួលបាន... | • ខ្ញុំកត់សម្គាល់ឃើញថាប្អូនហៅសិស្សដដែលៗឱ្យឆ្លើយសំណួរ ។<br>• វិធីនេះធ្វើឱ្យសិស្សដទៃទៀតចាប់ផ្ដើមជជែកគ្នា |
| | ៣.២.ធ្វើការបកស្រាយអំពីអ្វីដែលគ្រូណែនាំបានសង្កេតឃើញ | • ខ្ញុំគិតថា...<br>• ខ្ញុំយល់ថា...<br>• ខ្ញុំមានចំណាប់អារម្មណ៍ថា... | • ខ្ញុំគិតថាប្អូនមានការពិបាកក្នុងការគ្រប់គ្រងថ្នាក់<br>• ខ្ញុំឃើញថាប្អូនបានខិតខំកែលម្អការគ្រប់គ្រងថ្នាក់រៀន |

| | | | |
|---|---|---|---|
| ជំហានទី៤៖ ការចោទសួរឱ្យកម្មសិក្សាការីការិនីបញ្ចេញយោបល់លើអ្វីដែលបានលើកឡើង | ការឆ្លើយតបរបស់កម្មសិក្សាការី ការិនី (អាចជាសំណួរ គំនិតយោបល់ ឬថាតើកម្មសិក្សាការី ការិនីទទួលយកអ្វីដែលគ្រូណែនាំបាននិយាយ ឬទេ) | • តើប្អូនយល់ឃើញយ៉ាងដូចម្តេចខ្លះ?<br>• តើប្អូនគិតយ៉ាងដូចម្តេចចំពោះអ្វីដែលខ្ញុំបានលើកឡើង? | |
| ជំហានទី៥៖ ការពិភាក្សាគ្នារកមធ្យោបាយកែលម្អលទ្ធផលសម្រាប់អនុវត្តលើកក្រោយ | គ្រូណែនាំ និងកម្មសិក្សាការី ការិនីពិភាក្សារកដំណោះស្រាយ និងផ្តល់អនុសាសន៍ដើម្បីយកទៅអនុវត្ត | តើប្អូនត្រូវកែលម្អបញ្ហានេះយ៉ាងដូចម្តេចនៅពេលក្រោយ? ប្អូនគួរតែ.... | • ប្រហែលប្អូនអាចព្យាយាម...<br>• តើប្អូនគិតយ៉ាងណាចំពោះ...? |
| ជំហានទី៦៖ ការបូកសរុបដោយសួរសំណួរ និងកំណត់ពេលជួបលើកក្រោយ | ការបូកសរុប<br>សួរសំណួរ | • ឱ្យកម្មសិក្សាការី ការិនីសង្ខេបពីចំណុចដែលត្រូវអនុវត្តបន្ត<br>• សួរកម្មសិក្សាការី ការិនីប្រសិនបើគេមានសំណួរបន្ថែមទៀត | • ចូរប្អូនរៀបរាប់ពីអ្វីដែលយើងបានពិភាក្សាគ្នាថ្ងៃនេះ ។<br>• តើប្អូនមានអ្វីចង់សួរ ឬពិភាក្សាទៀតទេ? |
| | ការណាត់ជួបលើកក្រោយ | កំណត់កាលបរិច្ឆេទណាត់ជួបលើកក្រោយ | ខ្ញុំនឹងមកសង្កេតការបង្រៀនរបស់ប្អូន និងផ្តល់ព័ត៌មានត្រឡប់ទៀតនៅថ្ងៃទី... |

# ផ្នែកទី៤

# ការរៀបចំផ្តល់ព័ត៌មានត្រឡប់



# ផ្នែកទី៤: ការរៀបចំផ្តល់ព័ត៌មានត្រឡប់

**គោលបំណង:** បង្ហាញពីរបៀបរៀបចំផែនការដើម្បីឱ្យការផ្តល់ព័ត៌មានត្រឡប់ទទួលបានជោគជ័យ ។

ដើម្បីផ្តល់ព័ត៌មានត្រឡប់ឱ្យមានប្រសិទ្ធភាពខ្ពស់យើងត្រូវរៀបចំតាមដំណាក់កាលដូចខាងក្រោម៖

**DVD បំណិនព័ត៌មានត្រឡប់**

- វីដេអូទី៤៖ បង្ហាញពីទិដ្ឋភាពនៃការរៀបចំមិនបានល្អ
- វីដេអូទី៥៖ បង្ហាញពីទិដ្ឋភាពនៃការរៀបចំបានល្អ

## ៤.១ មុនពេលផ្តល់ព័ត៌មានត្រឡប់

- រៀបចំផែនការ
  - ជ្រើសរើសសាលារៀន និងពេលវេលា
  - ធ្វើការណាត់ជួបជាមួយកម្មសិក្សាការី ការិនី
  - កំណត់ប្រធានបទឱ្យបានច្បាស់លាស់
- ស្វែងយល់ និងប្រើប្រាស់គោលការណ៍ណែនាំ និងឧបករណ៍ផ្សេងៗឱ្យបានត្រឹមត្រូវ
  - បទបញ្ញត្តិ **និង**សេចក្តីណែនាំការអនុវត្តកម្មសិក្សាគរុកោសល្យ
  - ព្រឹត្តិបត្រសង្កេតការបង្រៀន
  - សៀវភៅសម្រាប់កត់ត្រា
- ពិនិត្យមើលកិច្ចតែងការបង្រៀនដែលកម្មសិក្សាការី ការិនីបានរៀបចំ
- សង្កេតការបង្រៀន និងរៀន
- រៀបចំកន្លែងអង្គុយ: គ្រូណែនាំត្រូវរៀបចំកន្លែងអង្គុយឱ្យបានសមរម្យ ព្រោះវាអាចជួយសម្រួលដល់ដំណើរការផ្តល់ព័ត៌មានត្រឡប់ឱ្យមានប្រសិទ្ធភាព ។ កាលណាអង្គុយជិតគ្នាពេកធ្វើឱ្យកម្មសិក្សាការី ការិនីភ័យខ្លាច តែបើអង្គុយឆ្ងាយពីគ្នាពេកធ្វើឱ្យកម្មសិក្សាការី ការិនីពិបាកស្តាប់ និងគ្មានការយកចិត្តទុកដាក់ ។



*ការរៀបចំកន្លែងអង្គុយបានល្អ*

- ចៀសវាងការរំខានពីបរិស្ថានជុំវិញៈ
  - **សំឡេងរំខានៈ** ម៉ាស៊ីន ការរំខានរបស់សិស្ស ទូរស័ព្ទពេទី មីក្រូ... ធ្វើឱ្យប៉ះពាល់ដល់ការស្តាប់ និងពិបាកក្នុងការទទួលយកព័ត៌មាន ។
  - **អាកាសធាតុៈ** ត្រជាក់ខ្លាំង ក្តៅខ្លាំង អាចជះឥទ្ធិពលដល់រាងកាយដែលធ្វើឱ្យលំបាក និងមានការបែកអារម្មណ៍ពីការស្តាប់ ។
  - **ពន្លឺៈ** ចេញចូលគ្រប់គ្រាន់ក្នុងបន្ទប់ ។

- ចៀសវាងការរំខានផ្នែកចិត្តសាស្ត្រៈ ការរំខានផ្នែកចិត្តសាស្ត្រគឺជាការរំខានដែលកើតចេញពីក្នុងចិត្តរបស់មនុស្ស ដូចជាមានអារម្មណ៍ ឃ្លាន អស់កម្លាំងខ្លាំង ឈឺចាប់ ការរំភើបពេក ។ល។ អារម្មណ៍ទាំងនេះអាចប៉ះពាល់ដល់ប្រសិទ្ធភាពនៃការផ្តល់ និងទទួលព័ត៌មានក្នុងដំណើរផ្តល់ព័ត៌មានត្រឡប់ ។ ប្រសិនបើគ្រូណែនាំមានអារម្មណ៍មិនល្អក្នុងពេលផ្តល់ព័ត៌មានត្រឡប់ ដែលធ្វើឱ្យគាត់ពិបាកស្តាប់ការលើកឡើងផ្សេងៗ របស់កម្មសិក្សាការី ការិនី ។

### ការរំខានផ្នែកចិត្តសាស្ត្រអាចមានៈ

- **ការគិតស្រមើស្រមៃៈ** ធ្វើឱ្យយើងមិនយកចិត្តទុកដាក់ស្តាប់ពេលនរណាម្នាក់កំពុងនិយាយព្រោះអារម្មណ៍របស់យើងកំពុងគិតទៅរឿងផ្សេង ។ បញ្ហានេះអាចបណ្តាលមកពីហេតុផលជាច្រើន ដូចជា អារម្មណ៍ធុញទ្រាន់នៅពេលដែលស្តាប់រឿងដែលមិនពាក់ព័ន្ធនឹងខ្លួន អារម្មណ៍កំពុងគិតទៅរឿងផ្សេង ខ្វះការយកចិត្តទុកដាក់ និងដេកមិនគ្រប់គ្រាន់ ។
- **បុរេវិនិច្ឆ័យៈ** ធ្វើឱ្យយើងមិនអាចទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ ពីព្រោះយើងសន្មតថាយើងបានដឹងនូវអ្វីដែលគេចង់និយាយចេញមក ។
- **ការគិតពីការងារច្រើនក្នុងពេលតែមួយៈ** ប្រសិនបើអ្នកធ្វើការងារច្រើនមុខពេកក្នុងពេលតែមួយ អ្នកពិតជាមិនផ្តោតការយកចិត្តទុកដាក់ស្តាប់បានល្អនោះទេ ។

## ៤.២ អំឡុងពេលផ្ដល់ព័ត៌មានត្រឡប់

អនុវត្តជំហានទាំង៦ នៃការផ្ដល់ព័ត៌មានត្រឡប់ ៖

1. សេចក្ដីផ្ដើម
2. ចំណាប់អារម្មណ៍របស់កម្មសិក្សាការី ការិនី លើលទ្ធផលនៃការបង្រៀន និងរៀន
3. ការផ្ដល់ព័ត៌មានត្រឡប់របស់គ្រូណែនាំ
4. ការចោទសួរឱ្យកម្មសិក្សាការី ការិនីបញ្ចេញយោបល់លើអ្វីដែលបានលើកឡើង
5. ការពិភាក្សាគ្នារកមធ្យោបាយកែលម្អលទ្ធផលសម្រាប់អនុវត្តលើកក្រោយ
6. ការបូកសរុប ដោយសួរសំណួរ និងកំណត់ពេលជួបគ្នាលើកក្រោយ។

**សម្គាល់:** កុំប្រើ ឬនិយាយទូរស័ព្ទពេលផ្ដល់ព័ត៌មានត្រឡប់ ។



## ៤.៣ ក្រោយពេលផ្ដល់ព័ត៌មានត្រឡប់

- សរសេររបាយការណ៍ឱ្យបានច្បាស់លាស់ ដោយរក្សាទុកសម្រាប់ខ្លួនឯង និងផ្ញើជូនអ្នកដែលពាក់ព័ន្ធ
- មានទំនាក់ទំនង និងពិភាក្សាជាមួយអ្នកពាក់ព័ន្ធដូចជាគ្រូឧទ្ទេស គ្រូប្រចាំថ្នាក់ និងគណៈគ្រប់គ្រងសាលារៀន ។

# III. ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ១៖ បញ្ជីសង្កេតសកម្មភាពនៃការស្ដាប់សកម្ម

លំហាត់ៈមើលវីដេអូការស្ដាប់មិនសកម្ម (វីដេអូទី១) និងការស្ដាប់សកម្ម (វីដេអូទី២)

ចូរគូសសញ្ញា ✓ លើចំណុចដែលអ្នកសង្កេតឃើញក្នុងវីដេអូនីមួយៗ

| គោលការណ៍នៃការស្ដាប់សកម្ម | | |
|---|---|---|
| | វីដេអូទី ១ | វីដេអូ ២ |
| 1. ការយកចិត្តទុកដាក់ | | |
| សម្លឹងមើលទៅកាន់អ្នកនិយាយ | | |
| ចៀសវាងមិនឱ្យមានការរំខានពីកត្តាផ្សេងៗ ដូចជា ទូរស័ព្ទ | | |
| សង្កេតមើល "ភាសាកាយវិការ" របស់អ្នកនិយាយ | | |
| 2. ឥរិយាបថកំពុងស្ដាប់ | | |
| ញញឹម ឬបង្ហាញទឹកមុខរីករាយ | | |
| បើកចិត្តឱ្យទូលាយដើម្បីទទួលយកព័ត៌មាន | | |
| អង្គុយឱ្យបានសមរម្យ | | |
| ផ្ដោតអារម្មណ៍ និងយល់ពីចិត្តរបស់អ្នកនិយាយ | | |
| ប្រើក្រសែភ្នែក | | |
| ងក់ក្បាលម្ដងម្កាល | | |
| លើកទឹកចិត្តអ្នកនិយាយតាមរយៈការនិយាយៈ ចាស៎ ឬ បាទ អូ ពិតមែនឬ... | | |
| 3. សង្ខេប និងសួរសំណួរបញ្ជាក់ | | |
| និយាយសង្ខេប "អ្វីដែលខ្ញុំបានស្ដាប់ឮគឺ..." ឬ " ស្ដាប់ទៅហាក់ដូចជាអ្នកចង់... | | |
| សួរសំណួរបញ្ជាក់ដូចជាៈ "តើអ្នកចង់មានន័យដូចម្ដេចនៅពេលដែលអ្នក... | | |
| 4. ចៀសវាងការវិនិច្ឆ័យ | | |
| មិននិយាយកាត់សម្ដី | | |
| ស្ដាប់គេនិយាយ ជាជាងធ្វើការវិនិច្ឆ័យ (ចូរប្រុងប្រយ័ត្នចំពោះការវិនិច្ឆ័យរបស់អ្នក!) | | |
| ទុកពេលឱ្យគេនិយាយឱ្យចប់ | | |
| 5. ការឆ្លើយតបឱ្យបានសមរម្យ | | |
| មិនលាក់លៀម បើកចិត្តឱ្យទូលាយ និងស្មោះត្រង់ចំពោះការឆ្លើយតបរបស់អ្នក | | |
| បញ្ជូលគំនិតរបស់អ្នកដោយការគោរព | | |
| ស្វែងយល់ពីស្ថានភាពរបស់អ្នកនិយាយ | | |

## ឧបសម្ព័ន្ធ២៖ ព្រឹត្តិបត្រសង្កេតសកម្មភាពផ្តល់ព័ត៌មានត្រឡប់

**កាលបរិច្ឆេទ:..................................................................**

**ព័ត៌មានទូទៅ**

អ្នកផ្តល់ព័ត៌មានត្រឡប់

- គ្រូឧទ្ទេស ☐ ប្រុស ☐ ស្រី មុខវិជ្ជាឯកទេស:.............................................................................................
- គ្រូប្រចាំថ្នាក់ ☐ ប្រុស ☐ ស្រី
- ផ្សេង (សូមបញ្ជាក់)...................................................................................................................

សាលាគរុកោសល្យ និងវិក្រឹតការរាជធានី និងខេត្ត...

- មណ្ឌលចុះកម្មសិក្សា៖................................................................
- កម្មសិក្សាការី ការិនីឆ្នាំទី:......................
- កម្មសិក្សាការី ការិនី: ទី១ភេទ៖............ ទី២ភេទ៖............ទី៣ភេទ៖...........ទី៤ភេទ៖..........
- បង្រៀនថ្នាក់ទី:..............................មុខវិជ្ជា:.................................................................
- សម្ភារៈដែលគរុសិស្សប្រើប្រាស់សម្រាប់កត់ត្រាការផ្តល់ព័ត៌មានត្រឡប់:..........................................................
  ...............................................................................................................................................
- ព្រឹត្តិបត្រ ឬសម្ភារៈដែលគ្រូណែនាំប្រើប្រាស់:.............................................................................................
- ម៉ោងចាប់ផ្តើមផ្តល់ព័ត៌មានត្រឡប់:....................ម៉ោងបញ្ចប់:..................... សរុប:............នាទី

<table>
<tr><td rowspan="2">ដំណាក់កាលទី១: សេចក្តីផ្តើម</td><td>១. គ្រូឧទ្ទេស ឬគ្រូប្រចាំថ្នាក់បានចាប់ផ្តើមដំណើរការផ្តល់ព័ត៌មានត្រឡប់ដោយបង្កើតបរិយាកាសល្អនិងស្និទ្ធស្នាល។</td><td colspan="4">☐ បាទ/ចាស់<br>☐ ទេ</td><td></td></tr>
<tr><td>២. គ្រូឧទ្ទេស ឬគ្រូប្រចាំថ្នាក់បានបង្ហាញពីគោលបំណង និងខ្លឹមសារនៃការផ្តល់ព័ត៌មានត្រឡប់នេះ ។</td><td colspan="4">☐ បាទ/ចាស់<br>☐ ទេ</td><td></td></tr>
<tr><td rowspan="3">ដំណាក់កាលទី២: ចំណាប់អារម្មណ៍របស់កម្មសិក្សាការី ការិនី លើលទ្ធផលនៃការបង្រៀន</td><td>៣. គ្រូឧទ្ទេស ឬគ្រូប្រចាំថ្នាក់បានឱ្យកម្មសិក្សាការី ការិនីឆ្លុះបញ្ចាំងលើសកម្មភាពបង្រៀន និងរៀនរបស់ខ្លួនមុននឹងចាប់ផ្តើមផ្តល់ព័ត៌មានត្រឡប់ ។</td><td colspan="4">☐ បាទ/ចាស់<br>☐ ទេ</td><td></td></tr>
<tr><td></td><td>មិនយល់ស្របទាំងស្រុង</td><td>មិនយល់ស្រប</td><td>យល់ស្រប</td><td>យល់ស្របទាំងស្រុង</td><td>មតិយោបល់</td></tr>
<tr><td>៤. គ្រូឧទ្ទេស ឬគ្រូប្រចាំថ្នាក់បានបំផុសកម្មសិក្សាការី ការិនីឱ្យធ្វើការឆ្លុះបញ្ចាំងពីដំណើរការបង្រៀន និងរៀន ពេលដែលពួកគេមិនបានឆ្លុះបញ្ចាំងឱ្យស៊ីជម្រៅលើចំណុចដែលគ្រូណែនាំចង់បាន ។</td><td></td><td></td><td></td><td></td><td></td></tr>
</table>

| | | | | | | |
|---|---|---|---|---|---|---|
| ជំហានទី៣: ការផ្ដល់ព័ត៌មានត្រឡប់ | ៥. គ្រូឧទ្ទេស ឬគ្រូប្រចាំថ្នាក់បានរៀបរាប់ច្បាស់លាស់អំពីវិធីសាស្រ្តបង្រៀនរបស់កម្មសិក្សាការី ការិនីដែលគាត់បានសង្កេតឃើញ ។ | | | | | |
| | ៦. គ្រូឧទ្ទេស ឬគ្រូប្រចាំថ្នាក់បានរៀបរាប់ច្បាស់លាស់អំពីឥរិយាបថរបស់កម្មសិក្សាការី ការិនីក្នុងពេលបង្រៀន។ | | | | | |
| | ៧. គ្រូឧទ្ទេស ឬគ្រូប្រចាំថ្នាក់បានបកស្រាយអំពីអ្វីដែលគាត់បានសង្កេតឃើញ ។ | | | | | |
| ជំហានទី៤: ការចោទសួរឱ្យកម្មសិក្សាការី ការិនីបញ្ចេញយោបល់ | ៨. គ្រូឧទ្ទេស ឬគ្រូប្រចាំថ្នាក់បានឱ្យកម្មសិក្សាការី ការិនីឆ្លើយតបទៅនឹងអ្វីដែលគាត់បានលើកឡើងតាមរយៈការសង្កេត និងការបកស្រាយរបស់គាត់ ។ | | | | | |
| | ៩. គ្រូឧទ្ទេស ឬគ្រូប្រចាំថ្នាក់បានស្ដាប់ដោយយកចិត្តទុកដាក់លើការលើកឡើង ឬប្រតិកម្មរបស់កម្មសិក្សាការី ការិនី ។ | | | | | |
| ជំហានទី ៥: ការពិភាក្សាគ្នារកមធ្យោបាយកែលម្អសម្រាប់អនុវត្តលើកក្រោយ | ១០. គ្រូឧទ្ទេស ឬគ្រូប្រចាំថ្នាក់បានលើកទឹកចិត្តកម្មសិក្សាការី ការិនីឱ្យចេះរកដំណោះស្រាយ ឬឥរិយាបថសមស្របដោយខ្លួនឯង ។ | | | | | |
| | ១១. គ្រូឧទ្ទេស ឬគ្រូប្រចាំថ្នាក់បានផ្ដល់ជាដំណោះស្រាយលើបញ្ហាផ្សេងៗដែលបានលើកឡើង ។ | | | | | |
| | ១២. គ្រូឧទ្ទេស ឬគ្រូប្រចាំថ្នាក់បានសង្ខេបឡើងវិញពីអ្វីដែលបានលើកឡើងក្នុងពេលផ្ដល់ព័ត៌មានត្រឡប់។ | | | | | |
| ជំហានទី ៦: ការបូកសរុប | ១៣. តើគ្រូឧទ្ទេស ឬគ្រូប្រចាំថ្នាក់បានទុកពេលឱ្យកម្មសិក្សាការី ការិនីសួរសំណួរដែលមានសេសសល់ផ្សេងៗទៀតដែរឬទេ? | ☐ បាទ/ចាស៎<br>☐ ទេ | | | | |
| | ១៤. តើគ្រូឧទ្ទេស ឬគ្រូប្រចាំថ្នាក់បានផ្ដល់មតិយោបល់ដល់កម្មសិក្សាការី ការិនីអំពីផែនការលើកក្រោយដែរឬទេ? | ☐ បាទ/ចាស៎<br>☐ ទេ | | | | |
| | ១៥. តើគ្រូឧទ្ទេស ឬគ្រូប្រចាំថ្នាក់បានឱ្យកម្មសិក្សាការី ការិនីនិយាយឡើងវិញអំពីចំណុចសំខាន់ៗដែលបានលើកឡើងពេលផ្ដល់ព័ត៌មានត្រឡប់ដែរឬទេ? | ☐ បាទ/ចាស៎<br>☐ ទេ | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | ១៦. តើគ្រូឧទ្ទេស ឬគ្រូប្រចាំថ្នាក់បានឱ្យកម្មសិក្សាការី ការិនីកត់ត្រាចំណុចសំខាន់ៗក្នុងពេលផ្តល់ព័ត៌មានត្រឡប់ដែរឬទេ? | ☐ បាទ/ចាស់<br>☐ ទេ | | | | |
| | ១៧. តើគ្រូឧទ្ទេស ឬគ្រូប្រចាំថ្នាក់បានប្រាប់កម្មសិក្សាការី ការិនីថាពេលណាត្រូវជួបគ្នាទៀតទេ? | ☐ បាទ/ចាស់<br>☐ ទេ | | | | |
| ចំណុចទី៤ | ១៨. ការផ្តល់ព័ត៌មានត្រឡប់មានភាពច្បាស់លាស់ និងជាក់លាក់ ។ | ច្បាស់លាស់ណាស់ | ច្បាស់លាស់ | អព្យាក្រិត | មិនច្បាស់លាស់ | មិនច្បាស់លាស់សោះ |
| | | | | | | |
| | ១៩. តើគ្រូឧទ្ទេស ឬគ្រូប្រចាំថ្នាក់បានផ្តល់ព័ត៌មានត្រឡប់ដល់កម្មសិក្សាការី ការិនី លើចំណុចខ្លាំងច្រើនជាង ឬចំណុចខ្សោយ ច្រើនជាង ? | តែចំណុចខ្សោយប៉ុណ្ណោះ | ភាគច្រើនលើចំណុចខ្សោយ | ទាំងចំណុចខ្លាំងនិងចំណុចខ្សោយស្មើគ្នា | ភាគច្រើនលើចំណុចខ្លាំង | តែចំណុចខ្លាំងប៉ុណ្ណោះ |
| | | | | | | |
| | ២០. តើអនុសាសន៍ទាំងនោះភាគច្រើនតាមបែបស្ថាបនា ឬភាគច្រើនតាមបែបបង្គាប់បញ្ជា? | បង្គាប់បញ្ជាណាស់ | បង្គាប់បញ្ជា | អព្យាក្រិត | ស្ថាបនា | ស្ថាបនាណាស់ |
| | | | | | | |
| **សេចក្តីសន្និដ្ឋាន** | | | | | | |

**អ្នកសង្កេត:**....................................................... **កាលបរិច្ឆេទ:**.............................................

## *សម្គាល់:*

*ព្រឹត្តិបត្រសង្កេតសកម្មភាពផ្តល់ព័ត៌មានត្រឡប់នេះ អាចត្រូវបានប្រើប្រាស់ដោយ៖*

- *ក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ)*
- *មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត*
- *គណ:កម្មការដឹកនាំកម្មសិក្សាគរុកោសល្យថ្នាក់រាជធានី ខេត្ត ខណ្ឌ ក្រុង ស្រុក*
- *គ្រូប្រចាំថ្នាក់និងគ្រូឧទ្ទេសអាចយកព្រឹត្តិបត្រនេះទៅប្រើប្រាស់ដើម្បីធ្វើស្វ័យវាយតម្លៃទៅលើប្រសិទ្ធភាពនៃការផ្តល់ព័ត៌មានត្រឡប់របស់ខ្លួន ។*

# ឯកសារយោង

## សៀវភៅ


- PAUL CAUTREELS (២០០៨) មាគ៌ាទៅកាន់អាជីពជាគ្រូបង្រៀនសម្រាប់គ្រូណែនាំ
- JEF CLEMENT (២០០៨) ការហ្វឹកហ្វឺនគរុកោសល្យ
- JOHN HATTIE & HELEN TIMPERLEY (២០០៧) ឥទ្ធិពលនៃការផ្តល់ព័ត៌មានត្រឡប់
- PORTNER HALL (២០០៣) ការណែនាំគ្រូចេញថ្មី


## គេហទំព័រ

ឯកសារផ្សេងៗទៀតដែលទាក់ទៅនឹងបំណិនផ្តល់ព័ត៌មានត្រឡប់


- http://rer.sagepub.com/content/77/1/81
- http://www.selfawareness.org.uk/news/understanding-the-johari-window-model
- http://www.mindtools.com/CommSkll/JohariWindow.htm

vvob
education for development

With the support of
THE BELGIAN
DEVELOPMENT COOPERATION
.be

With the support of
the governmernt of Flanders